# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៧-៩-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៩១៣/៨៩៨ ស្តីពី ការតែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភានីតិកាលទី ៣ ចំនួន ០៣ រូប ៨៤៨២

១៣-៩-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៩១៣/៨៩៩ ស្តីពី ការលើកលែងទោសឱ្យទណ្ឌិតឈ្មោះ សុផាប វង្សាប្រាក់ណា ៨៤៨៣

១៦-៩-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៩១៣/៩០០ ស្តីពី ការផ្ទេរបញ្ចូលឯកឧត្តម **ឈួរ ច័ន្ទឿន** ពីឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី នៃក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ ទៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៨៤៨៤

១៦-៩-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៩១៣/៩០១ ស្តីពី ការតែងតាំង ឯកឧត្តម **ឈួរ ច័ន្ទឿន** ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ ជា អភិបាល នៃគណៈអភិបាល ខេត្តកំពង់ឆ្នាំង ៨៤៨៥

២៣-៩-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៩១៣/៩០២ ស្តីពី ការតែងតាំង សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ៨៤៨៦

២៤-៩-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៩១៣/៩០៣ ស្តីពី ការបញ្ចប់តំណែងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលបានតែងតាំងដោយព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ហើយដែលបានកែសម្រួលដោយព្រះរាជក្រឹត្យជាបន្តបន្ទាប់មុនថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ និង តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពក្រសួង និងរដ្ឋលេខាធិការដ្ឋាន ៨៤៨៧

២៤-៩-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៩១៣/៩០៤ ស្តីពី ការបញ្ចប់តំណែងអនុរដ្ឋលេខាធិការគ្រប់រូបនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការតែងតាំងមុនថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ និង តែងតាំងឥស្សរជនចំនួន ២៣៥ រូប ជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា ៨៤៩៧

## II.ក្រុមប្រឹក្សាធម្មនុញ្ញ

០២-៩-២០១៣ -សេចក្តីសម្រេចលេខ ១៣៩/០១៤/២០១៣ កបធ.ច ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២៣០/០៣៤/២០១៣ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៣ ៨៥០៦
០៣-៩-២០១៣ -សេចក្តីសម្រេចលេខ ១៤០/០១៥/២០១៣ កបធ.ច ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២៣៧/០៤១/២០១៣ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៣ ៨៥១២
០៤-៩-២០១៣ -សេចក្តីសម្រេចលេខ ១៤១/០១៦/២០១៣ កបធ.ច ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២៣៨/០៤២/២០១៣ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៣ ៨៥២៤

## III.រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០១-៩-២០១៣ -អនុក្រឹត្យលេខ ៤៧៨ អនក្រ.បក ស្តីពី ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋផ្ទៃដីទំហំ ២១២៣,៩៩ ហិកតា ស្ថិតនៅភូមិសំអោង ឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រដែលគ្មានដី និងខ្វះដី ៨៥៤០
០៤-៧-២០១៣ -អនុក្រឹត្យលេខ ៨៦៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៥៤៤
០៤-៧-២០១៣ -អនុក្រឹត្យលេខ ៨៧០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៨៥៤៦
០៤-៧-២០១៣ -អនុក្រឹត្យលេខ ៨៧១ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៨៥៤៨
០៤-៧-២០១៣ -អនុក្រឹត្យលេខ ៨៧២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៥៥០
០៤-៧-២០១៣ -អនុក្រឹត្យលេខ ៨៧៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៨៥៥២
០៤-៧-២០១៣ -អនុក្រឹត្យលេខ ៨៧៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨៥៥៤
០៥-៧-២០១៣ -អនុក្រឹត្យលេខ ៨៧៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៥៥៥
០៥-៧-២០១៣ -អនុក្រឹត្យលេខ ៨៧៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៥៥៦
០៥-៧-២០១៣ -អនុក្រឹត្យលេខ ៨៧៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៥៥៧
០៥-៧-២០១៣ -អនុក្រឹត្យលេខ ៨៧៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៥៥៨

# គ

## IV~ការងារបណ្ដាក្រសួង

### ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


០៦-៩-២០១៣ -ប្រកាសលេខ ៨៥៦ សហវ.ប្រក ស្ដីពី ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ ស្ដីពីការរៀបចំ និងចាប់ផ្ដើមអនុវត្តអង្គភាពថវិកា ៨៥៥៩

១១-៩-២០១៣ -សេចក្ដីជូនដំណឹងលេខ ០១៥ សហវ.បាម ស្ដីពី ការផ្ទេរអតិរេកថវិការបស់រដ្ឋបាលឃុំ សង្កាត់ និង រដ្ឋបាលក្រុង ស្រុក ទៅក្នុងគណនីមូលនិធិបំរុងប្រើប្រាស់សម្រាប់ហិរញ្ញប្បទានឱ្យចំណាយជាមូលធននៃថវិកាឆ្នាំបន្ទាប់ ៨៥៦១


### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


១៦-៨-២០១៣ -ប្រកាសលេខ ៦៥១ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ថាមលេស ហ្វេសសិន ខ្លួស៊ីង បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៨៥៦២

១៩-៨-២០១៣ -ប្រកាសលេខ ៦៦៣ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជី អាន ផេភើរ (ខេមបូឌា) បង្កើតរោងចក្រ ផលិតកេសកាតុង ៨៥៦៦

១៩-៨-២០១៣ -ប្រកាសលេខ ៦៦៤ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន មេគង្គ ហ្គ្រីន ហ្វាម បង្កើតរោងចក្រ ផលិតជីរកៅស៊ូ ៨៥៧០

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០៩១៣/៨៩៤

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រមុខរដ្ឋស្តីទី

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | **ឈឿន** | **មុនី** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** |
| ២- ឯកឧត្តម | **តូច** | **បុប្ផាសារ៉ាដេត** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** |
| ៣- លោកជំទាវ | **ម៉ែងកា** | **ណូវេទនមិយ** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** |

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៣*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣រាល. ១៣០៩. ៩១២

លេខ: ៥៩៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**
**សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៣/៨៩៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានលើកលែងទោសឱ្យទណ្ឌិតឈ្មោះ សុជាប វង្សាប្រាក់ណា ភេទប្រុស អាយុ ៣៩ ឆ្នាំ ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារតាមអំណាចសាលក្រមស្ថាពរលេខ ០១ ចុះថ្ងៃទី ១២-០២-២០១០ របស់តុលាការយោធា ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស.១៣០៩.៩១៣

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៣

លេខៈ ៧៤៦ ២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៣/៩០០

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ទេរបញ្ចូលឯកឧត្តម **ឈួរ ច័ន្ទឡឿន** ពីឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី នៃក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ ទៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៧០៩.៩១៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣*

លេខ: ៧៩៤ ស.ណ

**សំណៅចំលងចេញតាមច្បាប់ដើម ដែលមានសេចក្ដីដូចច្បាប់ដើមសម្រាប់ការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១៣**
**អគ្គលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៣/៩០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ឈួរ ច័ន្ទឿន** ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ ជា **អភិបាល** នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១៣០៩.៩១៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១៣

លេខៈ ៩៩៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០១៣
**អគ្គលេខាធិការ [illegible] ទីស្តីការគណៈរដ្ឋមន្ត្រី**
**[illegible] សេង សុខា**

នស/រកត/០៩១៣/៩០៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/ ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់សេចក្តីសម្រេចលេខ ៤៦៩/១៣ គ.ជ.ប.សសរ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការប្រកាសលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ថ្ងៃអាទិត្យ ទី ២៨ ខែ កក្កដា ឆ្នាំ ២០១៣
- បានទ្រង់យល់សំណើរបស់គណបក្សប្រជាជនកម្ពុជា លេខ ៨៨៤ លគ.គក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ព្រឹទ្ធសមាជិករដ្ឋសភា នីតិកាលទី៥

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។**

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចរៀបចំសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសុំសេចក្តីអនុម័តទុកចិត្តពីរដ្ឋសភា។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានសៅ. ១៣០៩.៩១៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣*

លេខ: ៧៥៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
បដិជានីក្តាពេញ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៣/៩០៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៨/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៨ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០២ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

បញ្ចប់តំណែងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានតែងតាំងដោយព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ហើយដែលបានកែសម្រួលដោយព្រះរាជក្រឹត្យជាបន្តបន្ទាប់មុនថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ និងតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមាសភាពក្រសួង និងរដ្ឋលេខាធិការដ្ឋានដូចតទៅ ៖

**I- នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**II- ឧបនាយករដ្ឋមន្ត្រី**

១- ឯកឧត្តម ស ខេង

២- ឯកឧត្តម សុខ អាន

៣- ឯកឧត្តម ទៀ បាញ់

៤- ឯកឧត្តម គាត ឈន់ ប្រចាំការ

៥- ឯកឧត្តម ហោ ណាំហុង

៦- លោកជំទាវ ម៉ែន សំអន

៧- ឯកឧត្តម ប៊ិន ឈិន

៨- ឯកឧត្តម យឹម ឆៃលី

៩- ឯកឧត្តម កែ គឹមយ៉ាន

## III- **ទេសរដ្ឋមន្ត្រី**

១- ឯកឧត្តម អ៊ឹម ឈុនលឹម

២- ឯកឧត្តម ឆាយ ថន

៣- ឯកឧត្តម ចម ប្រសិទ្ធ

៤- ឯកឧត្តម ញឹម វណ្ណដា ( ទទួលបន្ទុកបេសកកម្មពិសេស )

៥- ឯកឧត្តម យុន ហាំង ( ទទួលបន្ទុកបេសកកម្មពិសេស )

៦- ឯកឧត្តម លី ធុជ ( ទទួលបន្ទុកបេសកកម្មពិសេស )

៧- ឯកឧត្តម ច័ន្ទ សារុន ( ទទួលបន្ទុកបេសកកម្មពិសេស )

៨- ឯកឧត្តម ស៊ិន ចាន់ថុល

៩- ឯកឧត្តម ឱម យ៉ិនទៀង ( ទទួលបន្ទុកបេសកកម្មពិសេស )

១០- ឯកឧត្តម អៀង ម៉ូលី ( ទទួលបន្ទុកបេសកកម្មពិសេស )

១១- ឯកឧត្តម វ៉ា គឹមហុង ( ទទួលបន្ទុកបេសកកម្មពិសេស )

១២- ឯកឧត្តម យឹម ណុលឡា ( ទទួលបន្ទុកបេសកកម្មពិសេស )

១៣- ឯកឧត្តម សេរី កុសល ( ទទួលបន្ទុកបេសកកម្មពិសេស )

១៤- ឯកឧត្តម ហ៊ឹម ឆែម ( ទទួលបន្ទុកបេសកកម្មពិសេស )

១៥- ឯកឧត្តម ជិន ប៊ុនសាន ( ទទួលបន្ទុកបេសកកម្មពិសេស )

## IV- **ក្រសួង-រដ្ឋលេខាធិការដ្ឋាន**

### ១- **ទីស្តីការគណៈរដ្ឋមន្ត្រី**

| | | |
|---|---|---|
| ១- | ឯកឧត្តម សុខ អាន | រដ្ឋមន្ត្រី |
| ២- | ឯកឧត្តម ប៊ុន អ៊ុយ | រដ្ឋលេខាធិការ |
| ៣- | ឯកឧត្តម ស៊ូ ភិរិន្ទ | រដ្ឋលេខាធិការ |
| ៤- | លោកជំទាវ ឆាយ វ៉ាន់នៀន | រដ្ឋលេខាធិការ |
| ៥- | ឯកឧត្តម ច័ន្ទ តានី | រដ្ឋលេខាធិការ |
| ៦- | ឯកឧត្តម ស្វាយ ស៊ីថា | រដ្ឋលេខាធិការ |
| ៧- | ឯកឧត្តម សុក ផេង | រដ្ឋលេខាធិការ |
| ៨- | ឯកឧត្តម យឹម បូរ | រដ្ឋលេខាធិការ |

| | | |
|---|---|---|
| ៩- | ឯកឧត្តម ព្រា សុចិន្តា | រដ្ឋលេខាធិការ |
| ១០- | ឯកឧត្តម ផៃ ស៊ីផាន | រដ្ឋលេខាធិការ |
| ១១- | ឯកឧត្តម អ៊ុនវីរជាតិ | រដ្ឋលេខាធិការ |
| ១២- | ឯកឧត្តម ហ៊ឹង ថូរ៉ាក់ស៊ី | រដ្ឋលេខាធិការ |
| ១៣- | ឯកឧត្តម តឹកវ៉េត សំរេច | រដ្ឋលេខាធិការ |
| ១៤- | ឯកឧត្តម កែវ រ៉េមី | រដ្ឋលេខាធិការ |
| ១៥- | ឯកឧត្តម ប៊ុន សំបូរ | រដ្ឋលេខាធិការ |
| ១៦- | ឯកឧត្តម ឃឹម រស្មីដា | រដ្ឋលេខាធិការ |
| ១៧- | ឯកឧត្តម ង៉ោ ហុងលី | រដ្ឋលេខាធិការ |

**២- ក្រសួងមហាផ្ទៃ**

| | | |
|---|---|---|
| ១- | ឯកឧត្តម ស ខេង | រដ្ឋមន្ត្រី |
| ២- | ឯកឧត្តម ឯម សំអាន | រដ្ឋលេខាធិការ |
| ៣- | ឯកឧត្តម ព្រុំ សុខា | រដ្ឋលេខាធិការ |
| ៤- | ឯកឧត្តម នុត សាអាន | រដ្ឋលេខាធិការ |
| ៥- | ឯកឧត្តម សក់ សេដ្ឋា | រដ្ឋលេខាធិការ |
| ៦- | ឯកឧត្តម ជី ច័ន្ទ្រផល | រដ្ឋលេខាធិការ |
| ៧- | លោកជំទាវ ជូ ប៊ុនអេង | រដ្ឋលេខាធិការ |
| ៨- | ឯកឧត្តម ប៉ុល លឹម | រដ្ឋលេខាធិការ |
| ៩- | ឯកឧត្តម តេង សាវង្ស | រដ្ឋលេខាធិការ |
| ១០- | ឯកឧត្តម ឌុល គឿន | រដ្ឋលេខាធិការ |
| ១១- | ឯកឧត្តម អ៊ុក គីមលេខ | រដ្ឋលេខាធិការ |

**៣- ក្រសួងការពារជាតិ**

| | | |
|---|---|---|
| ១- | ឯកឧត្តម ទៀ បាញ់ | រដ្ឋមន្ត្រី |
| ២- | ឯកឧត្តម ចាយ សាំងយុន | រដ្ឋលេខាធិការ |
| ៣- | ឯកឧត្តម ម៉ឹង សំផន | រដ្ឋលេខាធិការ |
| ៤- | ឯកឧត្តម នាង ផាត | រដ្ឋលេខាធិការ |
| ៥- | ឯកឧត្តម ឯលវ៉ាន់សារ៉ាត | រដ្ឋលេខាធិការ |
| ៦- | លោកជំទាវ ដាំ ដារីនី | រដ្ឋលេខាធិការ |

**៤- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

| | | |
|---|---|---|
| ១- | ឯកឧត្តម ហោ ណាំហុង | រដ្ឋមន្ត្រី |
| ២- | ឯកឧត្តម ឡុងវិសាលោ | រដ្ឋលេខាធិការ |
| ៣- | ឯកឧត្តម អ៊ុចបូររិទ្ធ | រដ្ឋលេខាធិការ |
| ៤- | ឯកឧត្តម ពូ សុធីរៈ | រដ្ឋលេខាធិការ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៥- ឯកឧត្តម អ៊ុង ស៊ាន រដ្ឋលេខាធិការ

៦- លោកជំទាវ សៀង រដ្ឋចារី រដ្ឋលេខាធិការ

**៥- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

១- ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រី

២- ឯកឧត្តម វង្សី វិស្សុត រដ្ឋលេខាធិការ

៣- ឯកឧត្តម ជូ វិជិត្ត រដ្ឋលេខាធិការ

៤- លោកជំទាវ ងួន សុខា រដ្ឋលេខាធិការ

៥- ឯកឧត្តម ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ

៦- ឯកឧត្តម ជី តាយី រដ្ឋលេខាធិការ

៧- ឯកឧត្តម ជូ គឹមឡេង រដ្ឋលេខាធិការ

**៦- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

១- ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រី

២- ឯកឧត្តម យុទ្ធ ភូថង រដ្ឋលេខាធិការ

៣- ឯកឧត្តម ឌិម គឹមស៊ា រដ្ឋលេខាធិការ

៤- ឯកឧត្តម ទី សុគន្ធ រដ្ឋលេខាធិការ

៥- ឯកឧត្តម ម៉ម អំណាត់ រដ្ឋលេខាធិការ

៦- លោកជំទាវ ហោ ម៉ាលីន រដ្ឋលេខាធិការ

**៧- ក្រសួងអភិវឌ្ឍន៍ជនបទ**

១- ឯកឧត្តម ជា សុផារ៉ា រដ្ឋមន្ត្រី

២- ឯកឧត្តម សួស គង់ រដ្ឋលេខាធិការ

៣- ឯកឧត្តម អ៊ិន ចន្ថា រដ្ឋលេខាធិការ

៤- ឯកឧត្តម សៅ ជីវន្ត រដ្ឋលេខាធិការ

៥- ឯកឧត្តម ទ្រី មេង រដ្ឋលេខាធិការ

៦- លោកជំទាវ ម៉ាត់ ម៉ារ៉ា រដ្ឋលេខាធិការ

**៨- ក្រសួងពាណិជ្ជកម្ម**

១- ឯកឧត្តម ស៊ុន ចាន់ថុល រដ្ឋមន្ត្រី

២- ឯកឧត្តម កឹម ស៊ីថន រដ្ឋលេខាធិការ

៣- ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការ

៤- ឯកឧត្តម ឌិក ប៊ុង រដ្ឋលេខាធិការ

៥- ឯកឧត្តម ម៉ៅ ថូរ៉ា រដ្ឋលេខាធិការ

៦- ឯកឧត្តម ឈូន ដារ៉ា រដ្ឋលេខាធិការ

៧- ឯកឧត្តម ឌិត ទីណា រដ្ឋលេខាធិការ

៨- លោកជំទាវ តឹកវ៉េត កំរង រដ្ឋលេខាធិការ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**៩- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

| | | |
|---|---|---|
| ១- | ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រី |
| ២- | ឯកឧត្តម អ៊ិត ប្រាំង | រដ្ឋលេខាធិការ |
| ៣- | ឯកឧត្តម សាត សាមី | រដ្ឋលេខាធិការ |
| ៤- | ឯកឧត្តម ភោគ សុវណ្ណរិទ្ធ | រដ្ឋលេខាធិការ |
| ៥- | ឯកឧត្តម ឯក សុនចាន់ | រដ្ឋលេខាធិការ |
| ៦- | ឯកឧត្តម ហេង សុខគង់ | រដ្ឋលេខាធិការ |
| ៧- | លោកជំទាវ ឡាយ ណាវីន | រដ្ឋលេខាធិការ |
| ៨- | ឯកឧត្តម គឹម ទូច | រដ្ឋលេខាធិការ |

**១០- ក្រសួងផែនការ**

| | | |
|---|---|---|
| ១- | ឯកឧត្តម ឆាយ ថន | រដ្ឋមន្ត្រី |
| ២- | ឯកឧត្តម ហ៊ូ តាំងអេង | រដ្ឋលេខាធិការ |
| ៣- | ឯកឧត្តម រិន វីរៈ | រដ្ឋលេខាធិការ |
| ៤- | ឯកឧត្តម សន ស៊ីថន | រដ្ឋលេខាធិការ |
| ៥- | ឯកឧត្តម ទូន ថាវរៈ | រដ្ឋលេខាធិការ |
| ៦- | លោកជំទាវ ប៉ែន សុបភា | រដ្ឋលេខាធិការ |
| ៧- | ឯកឧត្តម ប៉ាន ប៊ុនធឿន | រដ្ឋលេខាធិការ |

**១១- ក្រសួងអប់រំ យុវជន និងកីឡា**

| | | |
|---|---|---|
| ១- | ឯកឧត្តម ហង់ ជួនណារ៉ុន | រដ្ឋមន្ត្រី |
| ២- | ឯកឧត្តម ពិត ចំណាន | រដ្ឋលេខាធិការ |
| ៣- | ឯកឧត្តម ណាត ប៊ុនរឿន | រដ្ឋលេខាធិការ |
| ៤- | លោកជំទាវ គឹម សេដ្ឋានី | រដ្ឋលេខាធិការ |
| ៥- | ឯកឧត្តម ស៊ាន បូរ៉ាត | រដ្ឋលេខាធិការ |
| ៦- | ឯកឧត្តម អ៊ឹម កុច | រដ្ឋលេខាធិការ |
| ៧- | ឯកឧត្តម យក់ ង៉ុយ | រដ្ឋលេខាធិការ |

**១២- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

| | | |
|---|---|---|
| ១- | ឯកឧត្តម វង សូត | រដ្ឋមន្ត្រី |
| ២- | ឯកឧត្តម នឹម ថូត | រដ្ឋលេខាធិការ |
| ៣- | ឯកឧត្តម យី យ៉ូន | រដ្ឋលេខាធិការ |
| ៤- | ឯកឧត្តម សយ ស៊ីផុន | រដ្ឋលេខាធិការ |
| ៥- | ឯកឧត្តម មុត ខៀវ | រដ្ឋលេខាធិការ |
| ៦- | ឯកឧត្តម សែម សុខា | រដ្ឋលេខាធិការ |
| ៧- | ឯកឧត្តម អះម៉ាត់ យ៉ះយ៉ា | រដ្ឋលេខាធិការ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៨- ឯកឧត្តម ឃួន វ៉ានីន រដ្ឋលេខាធិការ

៩- លោកជំទាវ ខៀវ បូរី រដ្ឋលេខាធិការ

**១៣- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

១- ឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រី

២- ឯកឧត្តម ឆាន់ សាផាន រដ្ឋលេខាធិការ

៣- ឯកឧត្តម លឹម វ៉ាន់ រដ្ឋលេខាធិការ

៤- លោកជំទាវ អ៊ូ វ៉ នី រដ្ឋលេខាធិការ

៥- ឯកឧត្តម ភៀង សុភ័ណ្ឌ រដ្ឋលេខាធិការ

៦- ឯកឧត្តម សរ សុវណ្ណ រដ្ឋលេខាធិការ

៧- ឯកឧត្តម ប៉ែន សុផល រដ្ឋលេខាធិការ

**១៤- ក្រសួងបរិស្ថាន**

១- ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រី

២- ឯកឧត្តម ខៀវ មុត រដ្ឋលេខាធិការ

៣- ឯកឧត្តម យិន គិមស៊ាន រដ្ឋលេខាធិការ

៤- ឯកឧត្តម សាបូ អូហ្សព្រាណូ រដ្ឋលេខាធិការ

៥- លោកជំទាវ ឃុន លក្ស្មី រដ្ឋលេខាធិការ

**១៥- ក្រសួងធនធានទឹក និងឧតុនិយម**

១- ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រី

២- ឯកឧត្តម វេង សាខុន រដ្ឋលេខាធិការ

៣- ឯកឧត្តម តន់ វ៉ាន់ថាក់ រដ្ឋលេខាធិការ

៤- ឯកឧត្តម ប៊ុន ហ៊ាន រដ្ឋលេខាធិការ

៥- លោកជំទាវ សេង វណ្ណសាយ រដ្ឋលេខាធិការ

៦- ឯកឧត្តម ថោ ជេដ្ឋា រដ្ឋលេខាធិការ

**១៦- ក្រសួងព័ត៌មាន**

១- ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រី

២- ឯកឧត្តម អ៊ុក ប្រាថ្នា រដ្ឋលេខាធិការ

៣- ឯកឧត្តម មៅ អាយុទ្ធ រដ្ឋលេខាធិការ

៤- ឯកឧត្តម ថាច់ ផែន រដ្ឋលេខាធិការ

៥- ឯកឧត្តម នូវ សុវត្ថិរ៉ូ រដ្ឋលេខាធិការ

៦- ឯកឧត្តម ហោ សុភាព រដ្ឋលេខាធិការ

៧- ឯកឧត្តម ជា ចាន់បរិបូណ៌ រដ្ឋលេខាធិការ

៨- លោកជំទាវ ច័ន្ទ ធី រដ្ឋលេខាធិការ

**១៧- ក្រសួងយុត្តិធម៌**

១- ឯកឧត្តម អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រី

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- ឯកឧត្តម ហ៊ី សោភា រដ្ឋលេខាធិការ
៣- លោកជំទាវ ចាន់ សុទ្ធាវី រដ្ឋលេខាធិការ
៤- ឯកឧត្តម ង៉ោ សុវណ្ណ រដ្ឋលេខាធិការ
៥- ឯកឧត្តម ព្រហ្ម សិទ្ធត្រា រដ្ឋលេខាធិការ
៦- ឯកឧត្តម កើត រិទ្ធ រដ្ឋលេខាធិការ

**១៨- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**

១- លោកជំទាវ ម៉ែន សំអន រដ្ឋមន្ត្រី
២- ឯកឧត្តម ឆេង សារឿន រដ្ឋលេខាធិការ
៣- ឯកឧត្តម កង ណៃម រដ្ឋលេខាធិការ
៤- ឯកឧត្តម ថាច់ យន រដ្ឋលេខាធិការ
៥- ឯកឧត្តម ឌុច សុវណ្ណារី រដ្ឋលេខាធិការ
៦- លោកជំទាវ សុភ័ក្ត ថាវី រដ្ឋលេខាធិការ
៧- លោកជំទាវ សុខ វិឡាយ រដ្ឋលេខាធិការ

**១៩- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

១- ឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រី
២- ឯកឧត្តម សាវ៉ាក់ ខាន់ រដ្ឋលេខាធិការ
៣- ឯកឧត្តម ខាយ ឃុនហេង រដ្ឋលេខាធិការ
៤- ឯកឧត្តម ឯក វណ្ណឌី រដ្ឋលេខាធិការ
៥- លោកជំទាវ រស់ សូរក្ខា រដ្ឋលេខាធិការ
៦- ឯកឧត្តម កាន ច័ន្ទមេត្តា រដ្ឋលេខាធិការ
៧- លោកជំទាវ ប្រាក់ ច័ន្ទណាយ រដ្ឋលេខាធិការ

**២០- ក្រសួងសុខាភិបាល**

១- ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រី
២- ឯកឧត្តម ហេង តៃគ្រី រដ្ឋលេខាធិការ
៣- ឯកឧត្តម អ៊ឹង ភិរុន រដ្ឋលេខាធិការ
៤- ឯកឧត្តម អេង ហួត រដ្ឋលេខាធិការ
៥- ឯកឧត្តម សុខ ផេង រដ្ឋលេខាធិការ
៦- លោកជំទាវ តាន់ វួចឆេង រដ្ឋលេខាធិការ
៧- ឯកឧត្តម តែ គុយស៊ាង រដ្ឋលេខាធិការ
៨- ឯកឧត្តម ជូ យិនស៊ីម រដ្ឋលេខាធិការ
៩- ឯកឧត្តម ជា គ្រុយ រដ្ឋលេខាធិការ

**២១- ក្រសួងសាធារណការ និងដឹកជញ្ជូន**

១- ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រី
២- ឯកឧត្តម តូច ចាន់កុសល រដ្ឋលេខាធិការ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

៣- ឯកឧត្តម សួង ហេង រដ្ឋលេខាធិការ

៤- ឯកឧត្តម សួន រចនា រដ្ឋលេខាធិការ

៥- ឯកឧត្តម លឹម ស៊ីវេនីន រដ្ឋលេខាធិការ

៦- ឯកឧត្តម នូ សុវត្ថិ រដ្ឋលេខាធិការ

៧- ឯកឧត្តម សុខុម ភគវន្តមុនី រដ្ឋលេខាធិការ

៨- លោកជំទាវ មឺន មាណវី រដ្ឋលេខាធិការ

**២២- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

១- លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រី

២- ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការ

៣- ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ

៤- លោកជំទាវ ម៉ិញ កុសនី រដ្ឋលេខាធិការ

៥- ឯកឧត្តម អ៊ុក សុជាតិ រដ្ឋលេខាធិការ

៦- ឯកឧត្តម សោម សុគន្ធ រដ្ឋលេខាធិការ

៧- ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ

៨- ឯកឧត្តម សំរ៉ាំង កំសាន្ត រដ្ឋលេខាធិការ

**២៣- ក្រសួងទេសចរណ៍**

១- ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រី

២- ឯកឧត្តម សូ ម៉ារ៉ា រដ្ឋលេខាធិការ

៣- ឯកឧត្តម លី ប៊ុនធឿន រដ្ឋលេខាធិការ

៤- ឯកឧត្តម គោស៊ុំ សារឿត រដ្ឋលេខាធិការ

៥- លោកជំទាវ សម មុន្នីកា រដ្ឋលេខាធិការ

៦- ឯកឧត្តម ទិត ចន្ថា រដ្ឋលេខាធិការ

៧- ឯកឧត្តម ជា បូរ៉ា រដ្ឋលេខាធិការ

**២៤- ក្រសួងធម្មការ និងសាសនា**

១- ឯកឧត្តម មិន ឃិន រដ្ឋមន្ត្រី

២- ឯកឧត្តម ឡោក ជន រដ្ឋលេខាធិការ

៣- ឯកឧត្តម សុះ មុះសិន រដ្ឋលេខាធិការ

៤- ឯកឧត្តម នរៈរតនវឌ្ឍនោ រដ្ឋលេខាធិការ

៥- លោកជំទាវ ទូច សារ៉ុម រដ្ឋលេខាធិការ

**២៥- ក្រសួងកិច្ចការនារី**

១- លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រី

២- លោកជំទាវ ខេង សំវ៉ាដា រដ្ឋលេខាធិការ

៣- លោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការ

៤- លោកជំទាវ ច័ន្ទ សូរិយ៍ រដ្ឋលេខាធិការ

៥- លោកជំទាវ អ៊ុំ ស៊ីថៃ រដ្ឋលេខាធិការ
៦- លោកជំទាវ ស៊ី ដេហ្វីន រដ្ឋលេខាធិការ
៧- លោកជំទាវ សាន្ត អរុណ រដ្ឋលេខាធិការ
៨- លោកជំទាវ កុប ម៉ារីយ៉ាស រដ្ឋលេខាធិការ
៩- លោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការ

**២៦- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រី
២- ឯកឧត្តម ពេជ សោភ័ន រដ្ឋលេខាធិការ
៣- ឯកឧត្តម អូស្មាន ហាស្សាន់ រដ្ឋលេខាធិការ
៤- ឯកឧត្តម កាន់ ម៉ន រដ្ឋលេខាធិការ
៥- លោកជំទាវ ស៊ើង សរសុចិត្តា រដ្ឋលេខាធិការ
៦- ឯកឧត្តម អ៊ុំ មាន រដ្ឋលេខាធិការ
៧- ឯកឧត្តម ហ៊ុយ ហានសុង រដ្ឋលេខាធិការ
៨- ឯកឧត្តម ម៉ម វណ្ណៈ រដ្ឋលេខាធិការ

**២៧- ក្រសួងមុខងារសាធារណៈ**

១- ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រី
២- ឯកឧត្តម យូ ស៊ុនឡុង រដ្ឋលេខាធិការ
៣- ឯកឧត្តម អៀម សារុំ រដ្ឋលេខាធិការ
៤- ឯកឧត្តម រស់ សូផាន់ រដ្ឋលេខាធិការ
៥- លោកជំទាវ វ៉ាន់ ម៉ារ៉ា រដ្ឋលេខាធិការ
៦- ឯកឧត្តម ប៉ូល ពីខូ រដ្ឋលេខាធិការ
៧- ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការ

**២៨- រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

១- ឯកឧត្តម ហូ សិទ្ធី
២- ឯកឧត្តម សុខ ចិន្តាសោភា
៣- ឯកឧត្តម ម៉ម សារិន
៤- ឯកឧត្តម ស្រ៊ី ថាមរុង្គ
៥- ឯកឧត្តម ង៉ោ សុវណ្ណ
៦- ឯកឧត្តម ឈៀង យ៉ាណារ៉ា
៧- ឯកឧត្តម ឌុល គឿន
៨- ឯកឧត្តម យូ ស៊ុនឡុង
៩- ឯកឧត្តម អូស្មាន ហាស្សាន់
១០- ឯកឧត្តម សោម សឿន
១១- ឯកឧត្តម សុន គន្ធរ

១២- ឯកឧត្តម ហ្សាការីយ៉ា អាដាម

១៣- ឯកឧត្តម កៅគឹមហួន

**រដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

ឯកឧត្តម មៅ ហាវណ្ណាល់ រដ្ឋលេខាធិការ

**មាត្រា ២.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត/០៩១៣/៩១៧

លេខ:៨៩៧/ស.ណ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣

**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៣/៩០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

បញ្ចប់តំណែងអនុរដ្ឋលេខាធិការគ្រប់រូបនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការតែងតាំងមុនថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ និងតែងតាំងឥស្សរជនចំនួន ២៣៥រូប ជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានរាយនាមដូចខាងក្រោម ៖

**I- អំពីក្រសួង**

**១- ទីស្តីការគណៈរដ្ឋមន្ត្រី**

១- ឯកឧត្តម ហែម ក្រាញ់តូនី អនុរដ្ឋលេខាធិការ
២- ឯកឧត្តម ឈួន សុធី អនុរដ្ឋលេខាធិការ
៣- ឯកឧត្តម ជៀន ម៉ៅ អនុរដ្ឋលេខាធិការ
៤- ឯកឧត្តម ឡេង សេង អនុរដ្ឋលេខាធិការ
៥- ឯកឧត្តម អ៊ីវ ខេង អនុរដ្ឋលេខាធិការ
៦- ឯកឧត្តម ខឹម វិសិដ្ឋ អនុរដ្ឋលេខាធិការ
៧- ឯកឧត្តម បូន លឹមហេង អនុរដ្ឋលេខាធិការ
៨- លោកជំទាវ មាសសាឯម ដានី អនុរដ្ឋលេខាធិការ
៩- ឯកឧត្តម អ៊ុន ប៊ុណ្ណារ៉ា អនុរដ្ឋលេខាធិការ
១០- ឯកឧត្តម ឈឹម សៅគី អនុរដ្ឋលេខាធិការ

១១- ឯកឧត្តម ឃុន ជិនកេន អនុរដ្ឋលេខាធិការ

១២- ឯកឧត្តម អ៊ុម ស៊ីថុល អនុរដ្ឋលេខាធិការ

១៣- ឯកឧត្តម ហេ កាន់ អនុរដ្ឋលេខាធិការ

១៤- ឯកឧត្តម ថាវ គឹមឡុង អនុរដ្ឋលេខាធិការ

១៥- លោកជំទាវ ទុង សុគន្ធ អនុរដ្ឋលេខាធិការ

១៦- ឯកឧត្តម អាន ជាលី អនុរដ្ឋលេខាធិការ

**២- ក្រសួងមហាផ្ទៃ**

១- ឯកឧត្តម អ៊ុង សាមី អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ឈឹម ជួន អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ហេង ហាក់ អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម លូ រ៉ាមីន អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម លេង វី អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម ផុន ប៊ុនថាល់ អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម គឹម សុវណ្ណ អនុរដ្ឋលេខាធិការ

៨- ឯកឧត្តម ឡុង ផល អនុរដ្ឋលេខាធិការ

៩- ឯកឧត្តម សូវ ផន អនុរដ្ឋលេខាធិការ

១០- ឯកឧត្តម សុខ មុនី អនុរដ្ឋលេខាធិការ

១១- ឯកឧត្តម សួន ឈាងលី អនុរដ្ឋលេខាធិការ

១២- លោកជំទាវ ជួញ សុផៃ អនុរដ្ឋលេខាធិការ

១៣- ឯកឧត្តម មៀច សុផាន់ណា អនុរដ្ឋលេខាធិការ

**៣- ក្រសួងការពារជាតិ**

១- ឯកឧត្តម ឈុំ សុជាតិ អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ឃុន វុធ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ភួង ស៊ីផាន អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម ចៅ ផល្លី អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម ហ៊ុយ ពិសិដ្ឋ អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម កែវ ពង្ស អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម ស៊ូ គឹមស៊ុន អនុរដ្ឋលេខាធិការ

៨- ឯកឧត្តម សុខ ភាព អនុរដ្ឋលេខាធិការ

៩- ឯកឧត្តម សារ សុខ អនុរដ្ឋលេខាធិការ

១០- ឯកឧត្តម ដុម ហាក់ អនុរដ្ឋលេខាធិការ

១១- លោកជំទាវ ម៉ាលី សុជាតា អនុរដ្ឋលេខាធិការ

**៤- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

១- លោកជំទាវ អ៊ាត សោភា អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ជឹង ប៊ុនថេង អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម កុយ គួង អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម ស្មាន ម៉ាណាន អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម ស៊ុត ឌីណា អនុរដ្ឋលេខាធិការ

**៥- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

១- ឯកឧត្តម ញាណ ឡេង អនុរដ្ឋលេខាធិការ

២- ឯកឧត្តម សួង ម៉េងគា អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ឆាន់ វឌ្ឍនៈ អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម សុខ សារ៉ាវុឌ្ឍ អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម រស់ សីលវ៉ា អនុរដ្ឋលេខាធិការ

៦- លោកជំទាវ កែវ ចរិយា អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម វង់ សណ្តាប់ អនុរដ្ឋលេខាធិការ

៨- ឯកឧត្តម ហែម វណ្ណឌី អនុរដ្ឋលេខាធិការ

៩- ឯកឧត្តម ឈន សុភាព អនុរដ្ឋលេខាធិការ

**៦- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

១- ឯកឧត្តម សាន វណ្ណទី អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ចាន់ សុវុឌ្ឍ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម អ៊ឹង ហុកលីម អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម គិត សេង អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម អ៊ុំង កុសល អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម គង់ ចាន់ អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម ម៉ាន សុគ្រី អនុរដ្ឋលេខាធិការ

៨- លោកជំទាវ ម៉ុម ថានី អនុរដ្ឋលេខាធិការ

៩- ឯកឧត្តម សៅ វណ្ណសិរីវុទ្ធ អនុរដ្ឋលេខាធិការ

**៧- ក្រសួងអភិវឌ្ឍន៍ជនបទ**

១- ឯកឧត្តម សាន វិសាល អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ថោង ពោជ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ហួត សារឹម អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម ហាប់ អូម៉ាលី អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម ថេង ច័ន្ទសង្វារ អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម វ៉ាន់ ស៊ីវឿន អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម សុខ ម៉េង អនុរដ្ឋលេខាធិការ

៨- លោកជំទាវ ទេព បូរ៉ាមីន អនុរដ្ឋលេខាធិការ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

**៨- ក្រសួងពាណិជ្ជកម្ម**

| | |
|---|---|
| ១- ឯកឧត្តម វ៉េង សុធី | អនុរដ្ឋលេខាធិការ |
| ២- ឯកឧត្តម រាជ រ៉ា | អនុរដ្ឋលេខាធិការ |
| ៣- ឯកឧត្តម ហូ សារ៉ាន់ | អនុរដ្ឋលេខាធិការ |
| ៤- ឯកឧត្តម មាន សុភា | អនុរដ្ឋលេខាធិការ |
| ៥- លោកជំទាវ ចម និម្មល់ | អនុរដ្ឋលេខាធិការ |
| ៦- លោកជំទាវ កុយ សុដានី | អនុរដ្ឋលេខាធិការ |

**៩- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

| | |
|---|---|
| ១- ឯកឧត្តម ទឹង ស៊ីនី | អនុរដ្ឋលេខាធិការ |
| ២- ឯកឧត្តម កែ គី | អនុរដ្ឋលេខាធិការ |
| ៣- លោកជំទាវ ឃុន វ៉ារី | អនុរដ្ឋលេខាធិការ |
| ៤- ឯកឧត្តម សយ ភីរម្យ | អនុរដ្ឋលេខាធិការ |
| ៥- ឯកឧត្តម ហេង ចាន់ធូន | អនុរដ្ឋលេខាធិការ |
| ៦- ឯកឧត្តម ទុន លាន | អនុរដ្ឋលេខាធិការ |
| ៧- ឯកឧត្តម សុខ ឡេង | អនុរដ្ឋលេខាធិការ |
| ៨- ឯកឧត្តម អ៊ុច បូរ៉ា | អនុរដ្ឋលេខាធិការ |

**១០- ក្រសួងផែនការ**

| | |
|---|---|
| ១-ឯកឧត្តម វង្ស សាម៉ុន | អនុរដ្ឋលេខាធិការ |
| ២-ឯកឧត្តម នុត ច័ន្ទសុខា | អនុរដ្ឋលេខាធិការ |
| ៣-ឯកឧត្តម ទុយ ចំរើន | អនុរដ្ឋលេខាធិការ |
| ៤-ឯកឧត្តម អ៊ុក ប្រជា | អនុរដ្ឋលេខាធិការ |
| ៥-ឯកឧត្តម លេង ផាលី | អនុរដ្ឋលេខាធិការ |
| ៦-ឯកឧត្តម ហ៊ូ ហួរ | អនុរដ្ឋលេខាធិការ |
| ៧-ឯកឧត្តម ហោ ដារិទ្ធ | អនុរដ្ឋលេខាធិការ |
| ៨-លោកជំទាវ ដួង សារុន | អនុរដ្ឋលេខាធិការ |

**១១- ក្រសួងអប់រំ យុវជន និងកីឡា**

| | |
|---|---|
| ១- លោកជំទាវ ទន់ សាអ៊ីម | អនុរដ្ឋលេខាធិការ |
| ២- ឯកឧត្តម ប៊ូ ជុំសេរី | អនុរដ្ឋលេខាធិការ |
| ៣- ឯកឧត្តម ណុះ ស្លេះ | អនុរដ្ឋលេខាធិការ |
| ៤- ឯកឧត្តម ហ៊ាង ស៊ីណេ | អនុរដ្ឋលេខាធិការ |
| ៥- ឯកឧត្តម សាមឺឌី ស៊ីវឡែនា | អនុរដ្ឋលេខាធិការ |
| ៦- លោកជំទាវ ឃុន រចនា | អនុរដ្ឋលេខាធិការ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**១២- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

១- លោកជំទាវ ច័ន្ទហារ៉ាន់វឌ្ឍី អនុរដ្ឋលេខាធិការ

២- ឯកឧត្តម មុំ ប៊ុនថន អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ឈាង បាក់ អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម កែវ បូរេន្ទ្រ អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម ឆាយវណ្ណា អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម លឹម ឆាយ អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម ទៀវ សុគន្ធ អនុរដ្ឋលេខាធិការ

៨- ឯកឧត្តម សរ សុពុត្រា អនុរដ្ឋលេខាធិការ

**១៣- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

១- លោកជំទាវ ទិត្យ ច័ន្ទតារីន អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ទេព ធន អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ប៊ិន សម្បត្តិថាវ័ត្ន អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម យស់ ឆោមណារ៉ាឌី អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម ឌុច វនទិត្យ អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម ទា ច័ន្ទលីដា អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម អ៊ឹម ចំរុង អនុរដ្ឋលេខាធិការ

៨- ឯកឧត្តម កើត សារ៉េត អនុរដ្ឋលេខាធិការ

៩- ឯកឧត្តម សៀកវណ្ណា អនុរដ្ឋលេខាធិការ

១០- ឯកឧត្តម អ៊ិត សុត្ថា អនុរដ្ឋលេខាធិការ

**១៤- ក្រសួងបរិស្ថាន**

១- ឯកឧត្តម ស៊ិន ខ័ណ្ឌី អនុរដ្ឋលេខាធិការ

២- លោកជំទាវ មាស ម៉ូរ៉ែន អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ទា ជុប អនុរដ្ឋលេខាធិការ

៤- លោកជំទាវ ម៉ីប៊ុត វិទ្យា អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម ស៊ូ ស៊ូវុធ អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម សឹម យ៉ារ៉ែន អនុរដ្ឋលេខាធិការ

៧- លោកជំទាវ ព្រំ សុភី អនុរដ្ឋលេខាធិការ

**១៥- ក្រសួងធនធានទឹក និងឧតុនិយម**

១- ឯកឧត្តម ណី លន់ អនុរដ្ឋលេខាធិការ

២- ឯកឧត្តម លី ចាណា អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ហាក់ សុខមករា អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម ឃិន ងួនក្លលេនីន អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម រុន គូ អនុរដ្ឋលេខាធិការ

៦- លោកជំទាវ វ៉ាន់ ចាន់ថូ អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម គួច វែងស្រ៊ុន អនុរដ្ឋលេខាធិការ

**១៦- ក្រសួងព័ត៌មាន**

១- ឯកឧត្តម ហ៊ុយ សាវ៉ុង អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ថាច់ កេត អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម កែវ សុធា អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម សាន សំបូរ អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម ម៉ែន សាម៉ន អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម ហ៊ឹម សួង អនុរដ្ឋលេខាធិការ

៧- លោកជំទាវ នង បឿន អនុរដ្ឋលេខាធិការ

៨- ឯកឧត្តម មាស សុភ័ណ្ឌ អនុរដ្ឋលេខាធិការ

**១៧- ក្រសួងយុត្តិធម៌**

១- ឯកឧត្តម ប៉ុក ម៉ាន់នី អនុរដ្ឋលេខាធិការ

២- ឯកឧត្តម អ៊ិត រ៉ាឌី អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម សេង សុវណ្ណារ៉ា អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម ឈិត សារិទ្ធ អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម កែវ សុផល អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម គឹម សន្តិភាព អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម ជិន ម៉ាលីន អនុរដ្ឋលេខាធិការ

៨- លោកជំទាវ ខៀវ សុជានី អនុរដ្ឋលេខាធិការ

**១៨- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**

១- ឯកឧត្តម ស៊ុំ រុំ អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ខឹម ជាសោភ័ណ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ឃី មៅ អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម ទូច រិទ្ធី អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម ហួត ហាក់ អនុរដ្ឋលេខាធិការ

៦- លោកជំទាវ យក់ ណារ៉េត អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម ស៊ឹម ស៊ូយុង អនុរដ្ឋលេខាធិការ

**១៩- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

១- ឯកឧត្តម ទី ចន អនុរដ្ឋលេខាធិការ

២- ឯកឧត្តម កុយ ពុំ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម មាស ប៉ូ អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម ចាយ ណារុធ អនុរដ្ឋលេខាធិការ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៥- លោកជំទាវ ជ្រឹង បុទុមរង្សី អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម អេ សុភា អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម ខូវ មករា អនុរដ្ឋលេខាធិការ

**២០- ក្រសួងសុខាភិបាល**

១- ឯកឧត្តម ស៊ា ហួង អនុរដ្ឋលេខាធិការ

២- លោកជំទាវ គ្រុយ លាងស៊ីម អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម លី ឈួង អនុរដ្ឋលេខាធិការ

៤- លោកជំទាវ ប៉ែន រិកស៊ី អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម យឹម យ៉ាន់ អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម សាន់ សាប់អី អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម យឹត ស៊ុនណារ៉ា អនុរដ្ឋលេខាធិការ

៨- ឯកឧត្តម ញ៉ែម សូភៀន អនុរដ្ឋលេខាធិការ

៩- ឯកឧត្តម ឈូ អ៊ីម៉េង អនុរដ្ឋលេខាធិការ

១០- លោកជំទាវ អ៊ុំ សាម៉ុល អនុរដ្ឋលេខាធិការ

១១- ឯកឧត្តម កើត មៀច អនុរដ្ឋលេខាធិការ

**២១- ក្រសួងសាធារណការ និងដឹកជញ្ជូន**

១- ឯកឧត្តម ឡេង ធនយុទ្ធា អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ស្លួត សំបូរ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម មាស ម៉ូនីកា អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម កឹង មៅ អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម យិត បុណ្ណា អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម ហ៊ាន ប៊ុនធៀរ អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម អ៊ាង សុផល្លែត អនុរដ្ឋលេខាធិការ

៨- ឯកឧត្តម ញ៉ែម សារ៉ែន អនុរដ្ឋលេខាធិការ

៩- ឯកឧត្តម ព្រុំ ច័ន្ទសុវណ្ណារី អនុរដ្ឋលេខាធិការ

១០- ឯកឧត្តម អ៊ូន សុង អនុរដ្ឋលេខាធិការ

១១- ឯកឧត្តម ផេង សុវិជ្ជានោ អនុរដ្ឋលេខាធិការ

១២- លោកជំទាវ ម៉ម រមនា អនុរដ្ឋលេខាធិការ

**២២- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

១- លោកជំទាវ ឆឹង ស៊ីមន អនុរដ្ឋលេខាធិការ

២- ឯកឧត្តម គង់ កន្ធារ៉ា អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម អ៊ិន ទឹម អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម ស្រី សួន អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម ហ៊ឺ វីរៈ អនុរដ្ឋលេខាធិការ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៦- លោកជំទាវ នេត្រ ភូមារី អនុរដ្ឋលេខាធិការ

**២៣- ក្រសួងទេសចរណ៍**

១- ឯកឧត្តម ស្តើង សុខុម អនុរដ្ឋលេខាធិការ
២- ឯកឧត្តម ប៉ាក់ សុខុម អនុរដ្ឋលេខាធិការ
៣- ឯកឧត្តម ហោ សារុន អនុរដ្ឋលេខាធិការ
៤- ឯកឧត្តម ឱក តាភរិទ្ធិ អនុរដ្ឋលេខាធិការ
៥- ឯកឧត្តម នួន សុមេធ អនុរដ្ឋលេខាធិការ
៦- ឯកឧត្តម តុប សុភ័ក អនុរដ្ឋលេខាធិការ
៧- លោកជំទាវ ហ៊ុន ដានី អនុរដ្ឋលេខាធិការ
៨- ឯកឧត្តម វ៉ាត់ ចំរើន អនុរដ្ឋលេខាធិការ

**២៤- ក្រសួងធម្មការ និងសាសនា**

១- ឯកឧត្តម ញ៉ែម វ៉ាលី អនុរដ្ឋលេខាធិការ
២- ឯកឧត្តម សេង សុមុនី អនុរដ្ឋលេខាធិការ
៣- ឯកឧត្តម ហាក់ ប៊ុនធឿន អនុរដ្ឋលេខាធិការ
៤- ឯកឧត្តម ខិញ ហាង្សហួន អនុរដ្ឋលេខាធិការ
៥- លោកជំទាវ នួន ប៊ុនណា អនុរដ្ឋលេខាធិការ
៦- ឯកឧត្តម លន់ មុនីរតនា អនុរដ្ឋលេខាធិការ
៧- ឯកឧត្តម ទូ នីរ៉សេត អនុរដ្ឋលេខាធិការ
៨- ឯកឧត្តម អ៊ឹង វិបុល អនុរដ្ឋលេខាធិការ
៩- ឯកឧត្តម សាភយ ឆុន អនុរដ្ឋលេខាធិការ

**២៥- ក្រសួងកិច្ចការនារី**

១- លោកជំទាវ ញ៉ែម មរកត អនុរដ្ឋលេខាធិការ
២- លោកជំទាវ មាន ស្រីណូ អនុរដ្ឋលេខាធិការ
៣- លោកជំទាវ ឡូ គីម អនុរដ្ឋលេខាធិការ
៤- លោកជំទាវ ប៊ុន ពុទ្ធី អនុរដ្ឋលេខាធិការ
៥- លោកជំទាវ ឡុង សុផល្លី អនុរដ្ឋលេខាធិការ
៦- លោកជំទាវ ពេជ ពិទូរ្យរដ្ឋា អនុរដ្ឋលេខាធិការ
៧- លោកជំទាវ ទេស ច័ន្ទសាវឿន អនុរដ្ឋលេខាធិការ
៨- លោកជំទាវ យ៉យ នីតា អនុរដ្ឋលេខាធិការ

**២៦- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- ឯកឧត្តម ទុយ ស៊ីផាន់ អនុរដ្ឋលេខាធិការ
២- ឯកឧត្តម ឡេង សៃ អនុរដ្ឋលេខាធិការ
៣- ឯកឧត្តម សាត សមុទ្រ អនុរដ្ឋលេខាធិការ
៤- ឯកឧត្តម ហ៊ុ វុឌ្ឍី អនុរដ្ឋលេខាធិការ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

៥- ឯកឧត្តម ប៉ុក ប៉ាន់ អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម អៀង សុផល អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម ចាប ឫទ្ធី អនុរដ្ឋលេខាធិការ

៨- លោកជំទាវ សួស រដ្ឋារី អនុរដ្ឋលេខាធិការ

**២៧- ក្រសួងមុខងារសាធារណៈ**

១- លោកជំទាវ ឈី វិជ្ជរ៉ា អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ខៀវ ច័ន្ទប៊ុនធឿន អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ឈឿន ប៊ុណ្ណាវ័ត្ត អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម ជុក មុនី អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម ថោ សេដ្ឋាណា អនុរដ្ឋលេខាធិការ

៦- លោកជំទាវ សៅ សុគន្ធារី អនុរដ្ឋលេខាធិការ

**II- អំពីរដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

១- ឯកឧត្តម គឹម សុភ័ណ អនុរដ្ឋលេខាធិការ

២- ឯកឧត្តម សយ សុខាន់ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ប៊ុន នី អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម ជា អួន អនុរដ្ឋលេខាធិការ

៥- លោកជំទាវ ប៉ែន មុនីមករា អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម ពៅ ប៉ូលីណែល អនុរដ្ឋលេខាធិការ

**មាត្រា ២.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៣. ១៣០៩. ៩១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣

លេខៈ ៦៩៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៣០/០៣៤/២០១៣

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៣៩/០១៤/២០១៣ កបធ.ច

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញលិខិតលេខ ៨២១/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **ម៉ឺន ជួន** ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **ម៉ឺន ជួន** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តព្រះសីហនុ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៦៥/១៣ គ.ជ.ប ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **ម៉ឺន ជួន** កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ និងបញ្ជីរាយនាមប្រជាពលរដ្ឋ ចំនួន ៥២៩ នាក់ មានហុកសិបពីរទំព័រ ដែលដើមបណ្តឹងសំអាងថាជាភស្តុតាង
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ចំនួនពីរទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **ម៉ឺន ជួន** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ៥០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨២១/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អនុលោមតាមមាត្រា ១១៥ ថ្មី មាត្រា ១១៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ នៃមាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សា-ធម្មនុញ្ញ អាចទទួលពាក្យបណ្តឹងតវ៉ាខាងលើមកពិនិត្យបាន

- យល់ឃើញថា ពាក្យបណ្តឹងរបស់លោក **ម៉ឺន ជួន** ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ អមដោយឯកសារភស្តុតាងចំនួនហុកសិបពីរទំព័រ និង សារណាការពារពីរទំព័រទៀត ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ គឺទាមទារដូចតទៅ÷ ១-បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅមណ្ឌលខេត្តព្រះសីហនុ ២-ឱ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្តព្រះសីហនុឡើងវិញ ៣-ឱ្យរៀបចំបោះឆ្នោតសាជាថ្មីនៅខេត្តព្រះសីហនុ។ ដើមបណ្តឹងទាមទារយ៉ាងនេះដោយសំអាងថា នៅខេត្តព្រះសីហនុមានប្រជាពលរដ្ឋជាច្រើនបាត់ឈ្មោះពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ ដោយមិនដឹងមូលហេតុច្បាស់លាស់។ លោក **ម៉ឺន ជួន** បានឆ្លើយបញ្ជាក់ថា ការបោះឆ្នោតមណ្ឌលខេត្តព្រះសីហនុ ពុំមានអំពើហិង្សា ពុំមានចលាចលវឹកវរ ពុំមានការគំរាមកំហែងបង្ខឱ្យប្រជាពលរដ្ឋមានរបួសស្នាម និង ពុំមានករណីប្រធានសក្តិទេ។ រីឯក្នុងការិយាល័យបោះឆ្នោតប្រជាពលរដ្ឋពិតជាបានបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី។ ជាចុងក្រោយដើមបណ្តឹងស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញ ដោះស្រាយតាមនីតិវិធីដោយអនុគ្រោះ

- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ភ្ជាប់ដោយសារណាការពារចំនួនពីរទំព័រ បានបញ្ជាក់ថា បញ្ហាប្រជាពលរដ្ឋជាច្រើនត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោត ដែលអ្នកប្តឹងបានទទួលព័ត៌មានតាមការផ្តិតមេដៃរបស់ប្រជាពលរដ្ឋថា បាត់ឈ្មោះ ហើយអ្នកប្តឹងក៏គ្មានបញ្ជីឈ្មោះអ្នកទាំងអស់នោះដែរ។ ម្យ៉ាងវិញទៀតពួកអ្នកបាត់ឈ្មោះទាំងនោះ ក៏មិនបានបញ្ជាក់ថា ខ្លួនធ្លាប់មានឈ្មោះនៅការិយាល័យបោះឆ្នោតណាមួយនោះទេ ហើយបានទៅបោះឆ្នោតនៅការិយាល័យណាមួយនោះទេ។ បញ្ហាជនជាតិវៀតណាមជាច្រើនបានបោះឆ្នោត ដែលអ្នកប្តឹងបានព័ត៌មានពីភ្នាក់ងារគណបក្ស ហើយអ្នកប្តឹងក៏មិនបានដឹងថាមានប៉ុន្មាននាក់ ហើយក៏មិនបានដឹងថា បានបោះឆ្នោតនៅការិយាល័យណាដែរ។ បញ្ហាប្រជាពលរដ្ឋជាច្រើនបានរកការិយាល័យបោះឆ្នោតមិនឃើញ ដោយសារគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្តូរទីតាំងការិយាល័យបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមបញ្ជាក់ថា នៅខេត្តព្រះសីហនុ គ្មានការប្តូរទីតាំងការិយាល័យបោះឆ្នោតណាមួយនោះទេ។ បញ្ហាមានប្រជាពលរដ្ឋមួយចំនួនត្រូវបានគេបោះឆ្នោតជំនួស តែអ្នកប្តឹងមិនបានដឹងថាមានចំនួនប៉ុន្មាន ហើយនៅការិយាល័យណាមួយឡើយ។ បញ្ហាមានប្រជាពលរដ្ឋតែចំនួន ៨៧,៤៤៣ នាក់ ប៉ុណ្ណោះបានទៅបោះឆ្នោត ក្នុងបណ្តាអ្នកមានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោត ១២៦,៩៣៧ នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមបញ្ជាក់ថាការបោះឆ្នោតគឺជាការបោះឆ្នោតដោយស្ម័គ្រចិត្ត និង ទៅតាមសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួម

បោះឆ្នោត។ បញ្ហាភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ករណីនេះ អ្នកប្ដឹងមិនបានផ្ដល់ភស្ដុតាង ឯកសារ និង សាក្សីបញ្ជាក់ថា លិខិតទាំងអស់នោះត្រូវចេញនៅពេលណា ហើយក៏មិនបានបញ្ជាក់អំពីការិយាល័យបោះឆ្នោតដែលបានប្រើឯកសារមិនត្រឹមត្រូវនោះទេ។ បញ្ហាអ្នកសង្កេតការណ៍របស់គណបក្សសង្គ្រោះជាតិ ត្រូវបានដេញចេញឱ្យឆ្ងាយពីការិយាល័យ ហើយការិយាល័យមួយចំនួនបានបិទទ្វារបង្អួចពេលរាប់សន្លឹកឆ្នោត និង ការផ្ដល់ទម្រង់ ១២០២ សម្រាប់ការប្ដឹងតវ៉ាមានការយឺតយ៉ាវ ការលើកឡើងរបស់ដើមបណ្ដឹងក៏គ្មានអ្វីសម្រាប់សំអាងនោះឡើយ។ ចំពោះការតវ៉ាឬការជំទាស់នឹងការបាត់ឈ្មោះ លុបឈ្មោះ និង ការចុះឈ្មោះបោះឆ្នោតបានផុតអាជ្ញាយុកាលតាំងពីចុងឆ្នាំ២០១២ម្ល៉េះ

- យល់ឃើញថា ការទាមទារឱ្យបោះឆ្នោតសាជាថ្មីនៅមណ្ឌលខេត្តព្រះសីហនុ ដើមបណ្ដឹងពុំបានបង្ហាញទឡ្ហីករណ៍សមហេតុផលដូចមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១១១ ថ្មី និងមាត្រា ១១២ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ
- យល់ឃើញថា តាមការឆ្លើយបញ្ជាក់របស់លោក **ម៉ឺន ជួន** នៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញថា ការបោះឆ្នោតនៅមណ្ឌលខេត្តព្រះសីហនុ ពុំមានអំពើហិង្សា ពុំមានចលាចលវឹកវរ ពុំមានការគំរាមកំហែងបង្កឱ្យប្រជាពលរដ្ឋមានរបួសស្នាម និង ពុំមានករណីប្រធានសក្តិទេ។ រីឯនៅក្នុងការិយាល័យបោះឆ្នោតទាំងអស់ ប្រជាពលរដ្ឋពិតជាបានបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី
- យល់ឃើញថា ការបោះឆ្នោតនៅមណ្ឌលខេត្តព្រះសីហនុ សរុបមាន ២៤៨ ការិយាល័យ ការបោះឆ្នោតពុំមានករណីប្រធានសក្តិ ពុំមានអំពើហិង្សា និង ពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៦៨,៨៩ ភាគរយ
- យល់ឃើញថា លិខិតលេខ ៨២១/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្ដឹងរបស់លោក **ម៉ឺន ជួន** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

**មាត្រា ២.-** តម្កល់លិខិតលេខ ៨២១/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល។

**មាត្រា ៣.-** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល លេខ 230/034/2013 ថ្ងៃ 14 ស.ហ 2013 ម៉ោង 2h50

# ពាក្យបណ្តឹងតវ៉ា

ខ្ញុំបាទឈ្មោះ **ម៉ីន ជួន** អាយុ៥៥ឆ្នាំ ជាតំណាងគណបក្សសង្គ្រោះជាតិខេត្តព្រះសីហនុ មានទីលំនៅផ្ទះលេខ១៧២ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ:** ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តព្រះសីហនុ។

**យោង:** - លិខិតលេខ៨២១/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោត។
- ពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣
- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម សម រង្ស៊ី។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបាទ បានដាក់ពាក្យបណ្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទាមទារ:

១. ទាមទារបដិសេធលទ្ធផលនេះការបោះឆ្នោតនៅមណ្ឌលព្រះសីហនុ។

២. ទាមទារឲ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្តព្រះសីហនុឡើងវិញ។

៣. ទាមទារឲ្យបោះឆ្នោតឡើងវិញទូទាំងខេត្តព្រះសីហនុ។

ខ្ញុំបាទទាមទារយ៉ាងនេះដោយសំអាងថា:

១. នៅមណ្ឌលខេត្តព្រះសីហនុទាំងមូល មានប្រជាពលរដ្ឋជាច្រើនបាត់ឈ្មោះពីបញ្ជីបោះឆ្នោត ឆ្នាំ២០១២ ដោយមិនដឹងពីមូលហេតុច្បាស់លាស់។

ក្រោយពីបានដាក់ពាក្យបណ្តឹងមក នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំ។

ខ្ញុំបាទមិនសុខចិត្តនឹងការសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំចោលនេះទេ។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធាន មេត្តាទទួលយកនូវពាក្យបណ្តឹងតវ៉ារបស់ខ្ញុំបាទ ដើម្បីដោះស្រាយតាមនីតិវិធី ដោយសេចក្តីអនុគ្រោះ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣
**ហត្ថលេខា**

ម៉ីន. ជួន

*សូមជូនភ្ជាប់មកជាមួយនូវឯកសារថតចម្លង*

| | |
|---|---|
| - លិខិតលេខ៨២១/១៣ | ចំនួន០១ច្បាប់។ |
| - ពាក្យបណ្តឹង | ចំនួន០១ច្បាប់។ |
| - លិខិតផ្ទេរសិទ្ធិ | ចំនួន០១ច្បាប់។ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៣៧/០៤១/២០១៣

ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៤០/០១៥/២០១៣ កបធ.ច

ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញលិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **គួយ ប៊ុនរឿន** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងជំទាស់នឹងលិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនឯកឧត្តម **គួយ ប៊ុនរឿន** ធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៨០/១៣ គ.ជ.ប ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ របស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **គួយ ប៊ុនរឿន** កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយបញ្ជីឈ្មោះស្ទួនក្រៅ និង ក្នុងខេត្ត-រាជធានី ចំនួន៧,៩៨១សន្លឹក បញ្ជីបោះឆ្នោតស្ទួនចំនួន ០៨សីមី ស្នាមមេដៃប្រជាពលរដ្ឋបាត់បង់សិទ្ធិបោះឆ្នោតចំនួន០៨ដុំ លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើការបោះឆ្នោតនៅខេត្តព្រៃវែងចំនួន០១ដុំ និង របាយការណ៍របស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) ចំនួន០១ដុំ
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៣ មានចំនួនបីទំព័រ និង សេចក្តីបំភ្លឺបន្ថែមលើសារណាការពារចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ចំនួនមួយទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **គួយ ប៊ុនរឿន** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៣ និង ៥០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ ថ្មី មាត្រា ១១៧ ថ្មី

នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងតវ៉ារបស់ឯកឧត្តម **គួយ ប៊ុនរឿន** ប្តឹងមកក្រុមប្រឹក្សា-ធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ គឺតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយមានសំអាងប្រាំបីចំណុចប្រមូលផ្តុំលើបញ្ហាដូចតទៅ ÷ ១-បញ្ជីឈ្មោះបោះឆ្នោតផ្លូវការដែលមានសុពលភាពតាំងពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ២-ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើការបោះឆ្នោត ៣-ទឹកខ្មៅលុបលាងជ្រះ ៤-ប្រជាពលរដ្ឋគ្មានឯកសារបញ្ជាក់អត្តសញ្ញាណអាចបោះឆ្នោតបាន ៥-ការលុបឈ្មោះប្រជាពលរដ្ឋចេញពីបញ្ជីបោះឆ្នោត ៦-ការមិនអនុញ្ញាតឱ្យពលរដ្ឋមានអត្តសញ្ញាណប័ណ្ណបានបោះឆ្នោតដោយគ្រាន់តែលម្អៀងទិន្នន័យបន្តិចបន្តួចរវាងអត្តសញ្ញាណប័ណ្ណនឹងបញ្ជីឈ្មោះបោះឆ្នោត ៧-ការប្តូរការិយាល័យបោះឆ្នោត និង ៨-ការប្រើប្រាស់បណ្តាញសារព័ត៌មាន (វិទ្យុ ទូរទស្សន៍) មិនស្មើភាពគ្នា។ ដើមបណ្តឹងបានលើកសំណើបីចំណុចមកក្រុមប្រឹក្សាធម្មនុញ្ញគឺ ÷ ១-បដិសេធលិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ ទុកជាអាសារបង់ ២-ស៊ើបអង្កេតគ្រប់ករណីនៃភាពមិនប្រក្រតីដូចរៀបរាប់ក្នុងពាក្យបណ្តឹងឱ្យមានតម្លាភាព ដោយបង្កើតក្រុមការងារបច្ចេកទេស និង វាយតម្លៃភាពមិនប្រក្រតីដោយអង្គការសង្គមស៊ីវិលជាតិ និង អន្តរជាតិដែលមានជំនាញខាងកិច្ចការបោះឆ្នោត និង មានតំណាងរបស់អង្គការសហប្រជាជាតិជាអ្នកសង្កេតការណ៍ ៣-ធ្វើការកែតម្រូវលទ្ធផលនៃការបោះឆ្នោតឡើងវិញ

- យល់ឃើញថា ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារ មានខ្លឹមសារសង្ខេបដូចតទៅ ÷ ១-ដើមបណ្តឹងពុំមានភស្តុតាងជាក់លាក់អំពីចំណុចនៃភាពមិនប្រក្រតីនីមួយៗចំពោះការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតមិនប្រក្រតី មានអ្នកមកបោះឆ្នោតជំនួស និង ករណីទឹកខ្មៅលុបជ្រះនៅការិយាល័យណាមួយដែលអាចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យ និង វាយតម្លៃលើផលប៉ះពាល់បានឡើយ ២-ការបាត់ឈ្មោះ ឬមានឈ្មោះលើសពីមួយក្នុងបញ្ជីបោះឆ្នោត ឬឈ្មោះស្ទួន និង កែតម្រូវឈ្មោះក្នុងបញ្ជីបោះឆ្នោត គឺផុតអាជ្ញាយុកាលតវ៉ាតាំងពីចុងឆ្នាំ២០១២ម្ល៉េះ ៣-ដើមបណ្តឹងពុំមានភស្តុតាងដាក់ជូន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែល

បញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬសមាជិក គណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីទីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះនិងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀតដូចមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ ៤-ពុំមានភស្តុតាងបង្ហាញថា គណៈកម្មការបានអនុវត្តផ្ទុយពីមាត្រា ៧៤ និង មាត្រា ៧៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ ៥-ពុំមានច្បាប់ និង លិខិតបទដ្ឋានគតិយុត្តិណាដែលអាចឱ្យបង្កើតក្រុមការងារបច្ចេកទេសស៊ើបអង្កេត និង វាយតម្លៃភាពមិនប្រក្រតីនៃការបោះឆ្នោតជាតិ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលជាតិ និង អន្តរជាតិ ព្រមទាំងមានតំណាងអង្គការសហប្រជាជាតិជាអ្នកសង្កេតការណ៍ឡើយ ៦-ដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់ និង បូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងមណ្ឌលរាជធានី-ខេត្តត្រូវបានអនុវត្តតាមលំដាប់ថ្នាក់នៅ គឃ/សប គធ/ខប និង គ.ជ.ប ត្រឹមត្រូវស្របតាមច្បាប់ហើយ ៧-ពុំមានទឡ្ហីករណ៍ដាក់បន្ទុកដែលអាចឱ្យ គ.ជ.ប រៀបចំការបោះឆ្នោតសាជាថ្មី និង កែតម្រូវលទ្ធផលបោះឆ្នោតបានឡើយ ដូចមានចែងក្នុងមាត្រា ១១១ ថ្មី និង មាត្រា ១១២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ ៨-លិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ ធ្វើឡើងស្របតាមច្បាប់ និង ស្របតាមបទបញ្ជា និង នីតិវិធី។ ឯកឧត្តម **ឯម សូជាត** សំណូមពរសុំតម្កល់លិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល

- យល់ឃើញថា សំណូមពររបស់ឯកឧត្តម **គួយ ប៊ុនរឿន** សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បង្កើតក្រុមបច្ចេកទេសស៊ើបអង្កេត និង វាយតម្លៃភាពមិនប្រក្រតី ដោយមានអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិមានជំនាញខាងកិច្ចការបោះឆ្នោត ព្រមទាំងមានតំណាងរអង្គការសហប្រជាជាតិធ្វើជាអ្នកសង្កេតការណ៍ សំណើនេះមិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រពុំមានបទប្បញ្ញត្តិណាមួយអនុញ្ញាតឱ្យបង្កើតក្រុមបច្ចេកទេស ឬ គណៈកម្មការឯករាជ្យមានសមាសភាពដូចខាងលើធ្វើការស៊ើបអង្កេត វាយតម្លៃភាពមិនប្រក្រតីនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកម្ពុជាទេ
- យល់ឃើញថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ នៅក្នុង២៤មណ្ឌល ទូទាំងព្រះរាជាណាចក្រកម្ពុជា សរុបមាន ១៩,០០៩ ការិយាល័យ ការបោះឆ្នោត ពុំមានជួបករណីប្រធានសក្តិ ពុំមានអំពើហិង្សា និង ពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋទូទាំងព្រះរាជាណាចក្រកម្ពុជា បានបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៦៩,៦១ ភាគរយ

- យល់ឃើញថា លិខិតលេខ ៨៣០/១៣ គ.ជ.ប. ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.** ទទួលពាក្យបណ្តឹងរបស់ឯកឧត្តម **គួយ ប៊ុនរឿន** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់លិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

# គណបក្សសង្គ្រោះជាតិ
# CAMBODIA NATIONAL RESCUE PARTY

**សង្គ្រោះ បម្រើ ការពារ**

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ ...
ថ្ងៃ ...
ម៉ោង ...

## ពាក្យបណ្តឹង

ខ្ញុំ **គួយ ប៊ុនរឿន** ភេទប្រុស អាយុ ៤៦ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ១៦A ផ្លូវលេខ ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ លេខទូរស័ព្ទ ០១២ ៩១៧ ០៧០ តួនាទីតំណាងគណបក្សសង្គ្រោះជាតិ ។

**សូមគោរពជូន**
**ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ** ៖ ប្តឹងសុំតវ៉ានឹងសេចក្តីជូនដំណឹងការបដិសេធតាមរយៈលិខិត លេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប

**យោង** ៖ -មាត្រា ១៣៦ ថ្មី វាក្យខ័ណ្ឌ ២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-មាត្រា ២៥ ថ្មី មាត្រា ២៧ វាក្យខ័ណ្ឌ ២ និងមាត្រា ២៨ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-មាត្រា១៤ ថ្មី វាក្យខ័ណ្ឌ១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-ជំពូកទី៥ ចំណុច២ ចំណុច២-១ ចំណុច ក និងចំណុច ខ នៃសៀវភៅណែនាំស្តីពីនីតិវិធីដាក់/ទទួល និងដោះស្រាយពាក្យបណ្តឹងសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៣

-លិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលទទួលបាននៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៥ និង ០៨ នាទី។

ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញមេត្តាជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបានដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្របតាមកម្មវត្ថុនៃបណ្តឹង អង្គហេតុ ដែលបានកើតឡើង និងអង្គច្បាប់ ដែលមានក្នុងបណ្តឹងស្រាប់។ ប៉ុន្តែត្រូវបាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបដិសេធបណ្តឹងរបស់ខ្ញុំតាម លិខិតជូនដំណឹង លេខ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣។

សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតខាងលើនេះ មានភាពអយុត្តិធម៌ ដែលមិនអាចឲ្យគណបក្សសង្គ្រោះជាតិទទួលយកបានឡើយ ពីព្រោះថា យោងតាមមាត្រា ១៦ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក៏ដូចជាចំណុច ៣-៦ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ (ថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣) បានប្រគល់សិទ្ធិពេញលេញក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដើម្បី «ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់»។ ជាពិសេស គ.ជ.ប ត្រូវរៀបចំបញ្ជីបោះឆ្នោត និងផ្ទៀងបញ្ជីបោះឆ្នោតឲ្យមានសុក្រិតភាពបំផុត។ ប៉ុន្តែផ្ទុយទៅវិញ គ.ជ.បបានរំលោភច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ខ្លួនផ្ទាល់យ៉ាងធ្ងន់ធ្ងរ ដោយមិនបានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ អោយបានត្រឹមត្រូវ ហើយមិនអាចឆ្លុះបញ្ចាំងពីឆន្ទៈពិតប្រាកដរបស់ប្រជារាស្ត្របានទេ ដោយមានភាពមិនប្រក្រតីជាច្រើនបានកើតឡើងក្នុងថ្ងៃបោះឆ្នោត ពេលបោះឆ្នោត ពេលរាប់សន្លឹកឆ្នោត និងពេលប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតដែលគណបក្ស សង្គ្រោះជាតិបានស្រាវជ្រាវ និងប្រមូលភស្តុតាងនៃភាពមិនប្រក្រតីមួយចំនួន ដែលធ្វើអោយប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត និងអាសនៈរដ្ឋសភា។

ភាពមិនប្រក្រតីទាំងនោះមាន ៖

**I. ដំណាក់កាលមុនពេលបោះឆ្នោត ៖**

១. បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១២ សម្រាប់ការបោះឆ្នោតឆ្នាំ២០១៣

បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១២ សម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ ជាបញ្ជីបោះឆ្នោតមួយមិនមានតម្លាភាព គុណភាព និងសុវត្ថិភាពទេ ដោយសារតែ :

-បញ្ជីបោះឆ្នោតប៉ោង: តាមលទ្ធផលសិក្សាស្រាវជ្រាវរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យសំរាប់កិច្ចការអន្តរជាតិ NDI ឆ្នាំ២០១៣ បានរកឃើញថា មានឈ្មោះស្ទួនច្រើន (មនុស្សម្នាក់មានឈ្មោះនៅការិយាល័យច្រើន) មានឈ្មោះខ្មោចច្រើន (ឈ្មោះក្នុងបញ្ជីតែគ្មានរូបរាងមនុស្សពិតប្រាកដ) មានឈ្មោះអ្នកស្លាប់ច្រើន (ស្លាប់ហើយតែមិនលុបឈ្មោះចេញ) មានឈ្មោះអ្នកផ្លាស់ទីលំនៅច្រើន (ផ្លាស់ទីលំនៅចេញហើយតែមិនលុបឈ្មោះចេញ)

២.ភាពមិនប្រក្រតីនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសំរាប់បំរើការបោះឆ្នោត ៖

លិខិតបញ្ជាក់អត្តសញ្ញាណបំរាប់បម្រើឲ្យការបោះឆ្នោតនីតិកាលទី៥ ដោយមេឃុំ-ចៅសង្កាត់ ភាគច្រើនខុសនីតិវិធី ដូចជា ខ្លះគ្មានបំពេញអ្វីទាំងអស់ តែមានបោះត្រា និងចុះហត្ថលេខាមេឃុំ-ចៅសង្កាត់ រួចជាស្រេច។

បញ្ជីបោះឆ្នោតប៉ោង និងលិខិតបញ្ជាក់អត្តសញ្ញាណសំរាប់បម្រើការបោះឆ្នោត មិនប្រក្រតី គឺជាដៃគូជាយុទ្ធសាស្ត្រដ៏អាថ៌កំបាំង និងមានប្រសិទ្ធភាពបំផុតក្នុងការលួចបន្លំសន្លឹកឆ្នោត ហើយផ្តល់ឱកាសឲ្យ ៖

- អ្នកគ្មានសិទ្ធិបោះឆ្នោត បានសិទ្ធិបោះឆ្នោតដោយស្របច្បាប់ ។
- ជនមិនគ្រប់អាយុ (អាយុក្រោម ១៨ ឆ្នាំ) បានបោះឆ្នោតដោយស្របច្បាប់ ។

- ជនបរទេស (អន្តោប្រវេសន៍ខុសច្បាប់) បានបោះឆ្នោតដោយស្របច្បាប់។ ហើយតំណាងគណបក្សនយោបាយ មិនអាចចាប់កំហុសអ្នកទាំងនោះបានឡើយ ព្រោះបើតាមចំណុច ៨.៧.៣.៦ នៃបទបញ្ជា និងនីតិវិធីសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ បានចែងថា ៖ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា «មិនត្រូវណែនាំ ឬ សាកសួរអ្វី ចំពោះអ្នកបោះឆ្នោត» ។ ជាខ្លឹមសារ មានន័យថា ផ្តល់ឪកាស និងធានាដល់អ្នកប្រព្រឹត្ត ខាងលើអាចរួចផុតពីការផ្តន្ទាទោស។

ការដែលបើកឪកាសដល់អ្នកគ្មានសិទ្ធិបោះឆ្នោត (មិនស្របច្បាប់) យ៉ាងច្រើនលើសលុប បានសិទ្ធិបោះឆ្នោត(ដោយខុសច្បាប់) ធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលនៃការបោះឆ្នោត ដែលតម្រូវឲ្យគណបក្សសង្គ្រោះជាតិ ដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតទៅ គ.ជ.ប និងដាក់ពាក្យប្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតទៅក្រុមប្រឹក្សាធម្មនុញ្ញ ហើយស្ថាប័នទាំងពីរមិនត្រូវយកហេតុផលណាមួយ ដោយយកយន្តការ និងនីតិវិធី ក្នុងដំណាក់កាលបិទផ្សាយបញ្ជីឈ្មោះបោះឆ្នោត និងដំណាក់កាល នៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់បម្រើការបោះឆ្នោត ធ្វើជាមូលដ្ឋាន ដើម្បីបដិសេធ មិនទទួលយកពាក្យបណ្តឹងទៅដោះស្រាយនោះទេ។ ព្រោះបណ្តឹងដែលតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតខាងលើនេះ ជាបញ្ហានៃឫសគល់ដែលបណ្តាលឲ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ដោយសារការប្រើប្រាស់បញ្ជីបោះឆ្នោត មិនមានតម្លាភាព គុណភាព និងសុវត្ថិភាព និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើការបោះឆ្នោតមានភាពមិនប្រក្រតីដែលតម្រូវឲ្យមានការស៊ើបអង្កេតបញ្ជីបោះឆ្នោតឆ្នាំ២០១២ និងបញ្ជីបោះឆ្នោតដែលបានប្រើប្រាស់កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៣ ព្រមទាំងគល់បញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើការបោះឆ្នោត ប្រកបដោយតម្លាភាពបំផុត ដោយអង្គការឯករាជ្យមួយ ដោយមានគណបក្សទាំងពីរ អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ដែលមានជំនាញ ខាងកិច្ចការបោះឆ្នោត និងមានតំណាងរបស់ អ.ស.ប ជាអ្នកសង្កេតការណ៍ចូលរួមផងដែរ ។

### ៣.ការលុបឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតចេញពីបញ្ជីបោះឆ្នោត

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ មានប្រជាពលរដ្ឋជាច្រើនត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតមានចំនួន ១,៦៥៤,៥០២នាក់(លទ្ធផលសិក្សាស្រាវជ្រាវរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យសំរាប់កិច្ចការអន្តរជាតិ NDI ឆ្នាំ២០១៣) បានបាត់បង់សិទ្ធិបោះឆ្នោតដោយអយុត្តិធម៌ ដោយសារ គ.ជ.ប រំលោភលើបទបញ្ជា និងនីតិវិធី និងសេចក្តីណែនាំរបស់ខ្លួន។ ការដែលប្រជាពលរដ្ឋបាត់បង់សិទ្ធិ ហើយមិនបានបោះឆ្នោតនៅថ្ងៃបោះឆ្នោត គឺជាការកាត់បន្ថយសម្លេងគាំទ្រចំពោះគណបក្សសង្គ្រោះជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលនៃការបោះឆ្នោតផងដែរ ដែលតម្រូវឲ្យគណបក្ស

ង្គ្រោះជាតិដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតទៅ គ.ជ.ប និង ដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតទៅក្រុមប្រឹក្សាធម្មនុញ្ញ ហើយស្ថាប័នទាំងពីរមិនត្រូវយកហេតុណាមួយ(ពាក្យបណ្តឹងត្រូវធ្វើក្នុងរយៈពេលនៃការបិទផ្សាយបញ្ជីឈ្មោះដំបូង) ដើម្បីបដិសេធ មិនទទួលយកពាក្យបណ្តឹង ទៅដោះស្រាយនោះទេ ព្រោះជាពាក្យបណ្តឹងដែលតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតសុទ្ធសាធ ហើយបង្ហាញឫសគល់ ដែលធ្វើឲ្យប៉ះពាលដល់លទ្ធផលនៃការបោះឆ្នោត គឺការលុបឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតដែលគេយល់ថាគាំទ្រគណបក្សសង្គ្រោះជាតិចេញពីបញ្ជីបោះឆ្នោតដើម្បីកាត់បន្ថយសម្លេងគាំទ្រចំពោះគណបក្សសង្គ្រោះជាតិ ឲ្យបានច្រើនជាអតិបរមា ដែលតម្រូវឲ្យមានការស៊ើបអង្កេតប្រកបដោយតម្លាភាពដោយអង្គការឯករាជ្យខាងលើ។

**II. ដំណាក់កាលក្នុងពេលបោះឆ្នោត ៖**

**១.ទឹកខ្មៅលុបលាងជ្រះ**

បញ្ជីបោះឆ្នោតប៉ោង (ឈ្មោះស្ទួន) និងទឹកខ្មៅលុបលាងជ្រះ គឺជាការផ្តល់ឱកាសឲ្យ ៖

- អ្នកបោះឆ្នោតម្នាក់អាចបោះឆ្នោតបានច្រើនដង ដោយប្រើបញ្ជីឈ្មោះបោះឆ្នោតប៉ោង និងលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត។
- ដោយសារទឹកខ្មៅលុបលាងជ្រះនេះហើយ បានជានៅថ្ងៃបោះឆ្នោតមានសកម្មភាពនៃការដឹកជញ្ជូនជនចម្លែក (មនុស្សពុំទីលំនៅអចិន្ត្រៃយ៍នៅក្នុងឃុំ-សង្កាត់) ដែលបានបោះឆ្នោតនៅមួយកន្លែងហើយ ឲ្យទៅបោះឆ្នោតនៅមួយ ឬ ច្រើនកន្លែងទៀត ហើយបានកើតមានឡើងនៅទូទាំងប្រទេស ។
- មនុស្សម្នាក់អាចបោះឆ្នោតច្រើនលើសពីមួយ គឺជាការរំលោភច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ហើយក៏ការបង្កើនសម្លេងយ៉ាងច្រើនលើសលុបដល់គណបក្សផ្សេង។ ការបោះឆ្នោតមិនស្មើភាព និងមិនយុត្តិធម៌ដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផល នៃការបោះឆ្នោតដែលតម្រូវឲ្យមានការស៊ើបអង្កេតប្រកបដោយតម្លាភាព ដោយអង្គការឯករាជ្យដូចខាងលើ។

**២. អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មិនអាចបោះឆ្នោតបានដោយសារឈ្មោះរបស់ខ្លួនត្រូវអ្នកផ្សេងបោះជំនួស ៖**

ជាការកាត់បន្ថយសម្លេងគាំទ្រយ៉ាងច្រើនចំពោះគណបក្សសង្គ្រោះជាតិ ប៉ុន្តែផ្ទុយទៅវិញគឺជាការបង្កើនសម្លេងគាំទ្រយ៉ាងច្រើនដូចគ្នានេះចំពោះគណបក្សផ្សេងទៅវិញ ដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលនៃការបោះឆ្នោត ដែលតម្រូវឲ្យគណបក្សសង្គ្រោះជាតិដាក់ពាក្យបណ្តឹងតវ៉ាជាចាំបាច់ចំពោះពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដែលតម្រូវឲ្យមានការស៊ើបអង្កេត ដោយអង្គការឯករាជ្យដូចខាងលើ ។

**៣. អ្នកបោះឆ្នោតដែលមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មិនអាចបោះឆ្នោតបាន ដោយសារមានការកែទិន្នន័យខុសពីទិន្នន័យក្នុងបញ្ជីបោះឆ្នោត ៖**

ជាការកាត់បន្ថយសម្លេងគាំទ្រចំពោះគណបក្សសង្គ្រោះជាតិ មួយបែបទៀត។ ភាពលំអៀងបានកើតមានឡើង ដោយសារមានការលួច កែទិន្នន័យក្នុងបញ្ជីបោះឆ្នោតដោយចេតនានយោបាយពិតប្រាកដ ធ្វើឲ្យប៉ះពាល់ដល់លទ្ធផល នៃការបោះឆ្នោតយ៉ាងខ្លាំង ដែលតម្រូវឲ្យគណបក្សសង្គ្រោះជាតិ

ដាក់ពាក្យបណ្តឹងតវ៉ាជាចាំបាច់ ចំពោះពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងលទ្ធផលបណ្តោះ អាសន្ននៃការបោះឆ្នោត ដែលតម្រូវឲ្យមានការស៊ើបអង្កេត ដោយអង្គការឯករាជ្យដូចខាងលើ ។

៤. មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែមិនអាចបោះឆ្នោតបាន ដោយឈ្មោះរបស់ខ្លួនត្រូវបានប្តូរទៅការិយាល័យផ្សេង ៖

ការប្តូរការិយាល័យបោះឆ្នោតដោយមិនផ្តល់ប័ណ្ណព័ត៌មានបោះឆ្នោត ដល់ប្រជាពលរដ្ឋដែលគេយល់ថាគាំទ្រគណបក្សសង្គ្រោះជាតិ គឺជាចេតនានយោបាយរបស់អាជ្ញាធរមូលដ្ឋាន ដែលជាការដឹកនាំបញ្ហាច្បាស់លាស់ គឺជារបៀបកាត់បន្ថយសម្លេងគាំទ្រចំពោះគណបក្សសង្គ្រោះជាតិ ហើយធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ដែលតម្រូវឲ្យគណបក្សសង្គ្រោះជាតិដាក់ពាក្យបណ្តឹងតវ៉ាជាចាំបាច់ ចំពោះពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដែលតម្រូវឲ្យមានការស៊ើបអង្កេត ដោយអង្គការឯករាជ្យដូចខាងលើ ។

៥.ការអនុញ្ញាតឲ្យបោះឆ្នោត ចំពោះអ្នកបោះឆ្នោតដែលគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ ដែលបានកំណត់ដោយបទបញ្ញា និងនីតិវិធីរបស់ គ.ជ.ប ៖

- ជាការជួយប្រមូលសម្លេងគាំទ្រដល់គណបក្សផ្សេង។
- ការអនុញ្ញាតដល់ប្រជាពលរដ្ឋ ដែលគេដឹងច្បាស់ថា គាំទ្រគណបក្សផ្សេងបានធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ។

៦.ការប្រើប្រាស់បណ្តាញសារព័ត៌មាន (វិទ្យុ ទូរទស្សន៍) យ៉ាងច្រើនលើសលុប ដោយគណបក្សផ្សេង ហើយគណបក្សសង្គ្រោះជាតិប្រើប្រាស់វិទ្យុបានតិចតួចបំផុតនោះគឺ ៖

ជាការបោះឆ្នោតមិនស្មើភាព មិនយុត្តិធម៌ ហើយប្រជាពលរដ្ឋ មិនអាចទទួលព័ត៌មានបានគ្រប់ជ្រុងជ្រោយ ដែលនាំឲ្យពួកគាត់ធ្វើសេចក្តីសម្រេចចិត្តខុស និងធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតផងដែរ ។

## III. ការឆ្លើយចំពោះការបញ្ជាក់របស់ គ.ជ.ប ៖

១. ការបាត់ឈ្មោះ ឬមានឈ្មោះលើសពីមួយក្នុងបញ្ជី ឬ កែតម្រូវឈ្មោះ ឈ្មោះស្ទួន និងកែតម្រូវឈ្មោះក្នុងបញ្ជីបោះឆ្នោត គឺត្រូវប្តឹងតវ៉ា ឬ ប្តឹងជំទាស់ នៅក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ គឺជាចម្លើយមិនឆ្លើយតបទៅនឹងកម្មវត្ថុបណ្តឹងទេ ព្រោះខ្ញុំបានប្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោត ហើយបង្ហាញនូវឫសគល់ដែលបណ្តាលឲ្យប៉ះពាលដល់លទ្ធផលនៃការបោះឆ្នោត គឺបញ្ជីឈ្មោះប៉ោង ដែលមានមូលហេតុដូចបានរៀបរាប់ក្នុងពាក្យបណ្តឹងខាងលើនេះស្រាប់ មិនមែនបណ្តឹងតវ៉ាពីការបាត់ឈ្មោះ ឬ ប្តឹងជំទាស់ពីការលើសឈ្មោះ កែតម្រូវឈ្មោះ ឈ្មោះស្ទួនដែល ត្រូវធ្វើនៅក្នុងអំឡុងពេលពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំនោះទេ។ (ឯកសារភស្តុតាងបានប្រគល់ជូន គ.ជ.ប រួចហើយ) ។

ដូច្នេះ គ.ជ.ប ត្រូវតែដោះស្រាយបណ្តឹងឲ្យបានសមស្រប ដើម្បីឆ្លើយតបទៅនឹងមាត្រា ១៦ ថ្មី វាក្យខ័ណ្ឌ ១ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានចែងថា ត្រូវ «ចាត់វិធានការគ្រប់រូបភាពដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់»។ ហើយមិនត្រូវបិទបាំងកំហុសខ្លួនឯង ហើយទំលាក់កំហុសខ្លួនឯង ទៅលើប្រជាពលរដ្ឋនេះ

ទេ ព្រោះប្រជាពលរដ្ឋបានទៅចុះឈ្មោះហើយ ប៉ុន្តែហេតុអ្វីបានជាបាត់ឈ្មោះ មានឈ្មោះស្ទួន មានខុសឈ្មោះ ពិសេសបញ្ជីបោះឆ្នោតប៉ោងមិនមែនប្រជាពលរដ្ឋត្រូវទទួលខុសត្រូវចំពោះភាពមិនប្រក្រតីទាំងនោះទេ គឺ គ.ជ.ប ទេ ដែលជាអ្នកទទួលខុសត្រូវដូចមានកំណត់ក្នុងមាត្រា ១៦ វាក្យខ័ណ្ឌ១ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុច ៣.៦.១ នៃបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ស្រាប់ ។

២- ចំពោះភាពមិនប្រក្រតី នៃកាចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត និងទឹកខ្មៅលុបជ្រះជាការបង្ហាញ ដល់មតិទូទៅ (មតិជាតិ និងអន្តរជាតិ) បានដឹងយ៉ាងច្បាស់ហើយ ប៉ុន្តែគ្រាន់តែគ្មានភស្តុតាងច្បាស់លាស់ ដែលតម្រូវឲ្យមានការស៊ើបអង្កេតប្រកបដោយតម្លាភាពមួយ អាស្រ័យហេតុនេះហើយ បានជានៅក្នុងពាក្យបណ្តឹងរបស់ខ្ញុំបាទ បានស្នើសុំឲ្យបង្កើតក្រុមការងារបច្ចេកទេសឯករាជ្យមួយ ដើម្បីស៊ើបអង្កេត និងវាយតម្លៃលើភាពមិនប្រក្រតីទាំងអស់នៃការបោះឆ្នោត។

៣- ចំណែកឯការប្រើប្រាស់បណ្តាញសារព័ត៌មាន (វិទ្យុ ទូរទស្សន៍) ច្រើនលើសលុបដោយ គណបក្សផ្សេង គឺបានកើតមានឡើងជារៀងរាល់ថ្ងៃ គ្រប់មូលដ្ឋាន ហើយបានធ្វើឲ្យប៉ះពាល់ដល់លទ្ធផល នៃការបោះឆ្នោតយ៉ាងខ្លាំង។

ខ្ញុំគ្មានប្រយោជន៍អ្វីត្រូវចោទប្រកាន់ថា គ.ជ.ប បានអនុវត្តផ្ទុយនឹងមាត្រា ៧៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងប្រការ ៧.១៦ នៃបទបញ្ជា និងនីតិវិធី របស់ គ.ជ.ប នោះទេ។ បណ្តឹងរបស់ខ្ញុំ គឺតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដែលត្រូវបានប៉ះពាល់យ៉ាងខ្លាំងដោយការប្រើប្រាស់បណ្តាញសារព័ត៌មាន យ៉ាងច្រើនលើសលុបរបស់គណបក្សផ្សេង អ្វីដែលខ្ញុំចង់និយាយ គឺការបោះឆ្នោតមិនស្មើភាព និងមិនយុត្តិធម៌ ។

៤. ចំពោះចម្លើយដែលថា ៖ «ពុំមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិណាដែលអាចឲ្យបង្កើតក្រុមការងារបច្ចេកទេស និងវាយតម្លៃភាពមិនប្រក្រតីដោយមានអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ដែលមានជំនាញខាងកិច្ចការបោះឆ្នោត និងមានតំណាងរបស់ អ.ស.ប ជាអ្នកសង្កេតការណ៍ឡើយ» នោះមិនមែនជាឧបករណ៍ ឬ ជារបាំងដាច់ខាត ដែលមិនអាចកែប្រែបានឡើយ ។ ដើម្បីសិទ្ធិសេរីភាពមនុស្ស និងយុត្តិធម៌សង្គម ឲ្យកាន់តែប្រសើរថែមទៀត ក្នុងការបោះឆ្នោត គ.ជ.ប មានសមត្ថកិច្ច និងភារកិច្ចក្នុងការរៀបចំយន្តការ និងនីតិវិធីពិសេស ដើម្បីធានានិងបង្ហាញអំពីការទទួលខុសត្រូវ និងបង្ហាញពីតម្លាភាពក្នុងការរៀបចំការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

៥. ឆ្លើយតបចម្លើយទី៥ របស់ គ.ជ.ប ខ្ញុំមានភស្តុតាងច្បាស់លាស់ណាស់ គឺប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ហើយពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មានចំនួន ១,៦៥៤,៥០២ នាក់ (លទ្ធផលស្រាវជ្រាវរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ NDI ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣) ដែលជាអង្គការ ឯករាជ្យ និងមានកិត្តិយសខ្ពង់ខ្ពស់។ (ឯកសារភស្តុតាង និងស្នាមមេដៃបានប្រគល់ជូន គ.ជ.ប រួចហើយ) ។

ផ្អែកតាមភាពមិនប្រក្រតីធ្ងន់ធ្ងរខាងលើ ខ្ញុំសូមឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញមេត្តា ៖

- បដិសេធលិខិតជូនដំណឹងរបស់ គ.ជ.ប តាមលិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ ទុកជាអាសារបង់ ។

- ស៊ើបអង្កេតគ្រប់ករណីនៃភាពមិនប្រក្រតីដូចបានរៀបរាប់ក្នុងបណ្តឹងនេះ ឲ្យមានតម្លាភាព ដោយបង្កើតក្រុមការងារបច្ចេកទេស និងវាយតម្លៃភាពមិនប្រក្រតីដោយអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ដែលមានជំនាញខាងកិច្ចការបោះឆ្នោត និងមានតំណាងរបស់ អ.ស.ប ជាអ្នកសង្កេតការណ៍ ។
- ធ្វើការកែតម្រូវលទ្ធផលនៃការបោះឆ្នោតឡើងវិញ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ៕

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

ស្នាមមេដៃស្តាំ

គួយ ប៊ុនរឿន

សូមជូនភ្ជាប់មកជាមួយនូវ ៖

- លិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)
- ពាក្យបណ្តឹងចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម គួយ ប៊ុនរឿន (សំណុំរឿងលេខ ០៩២/១៣ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣
- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៣៨/០៤២/២០១៣

ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៤១/០១៦/២០១៣ កបធ.ច

ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ របស់លោក **សួន ចំរើន** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងសុំតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ផ្ទេរសិទ្ធិជូនលោក **សួន ចំរើន** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញទៅតាមនីតិវិធីច្បាប់
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៧៩/១៣ គ.ជ.ប ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **សួន ចំរើន** កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ ភ្ជាប់ដោយឯកសារថតចម្លងទម្រង់ ១១០៤ ចំនួនពីររយសាមសិបបីសន្លឹក
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ អមដោយសារណាការពារចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣ ចំនួនពីរទំព័រ
- បានឃើញសេចក្តីសម្រេចលេខ ២៩/២០១៣ កបធ.សសរ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តបាត់ដំបង
- បានឃើញលិខិតលេខ ០៤៤/២០១៣ កបធ.ច ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ ចាត់តាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ៣រូប ដើម្បីចូលរួមស្រាវជ្រាវ ស៊ើបអង្កេតការបើកកញ្ចប់សុវត្ថិភាព" ក "នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុស្តីពីការផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព " ក " មួយចំនួននៅមណ្ឌលខេត្តបាត់ដំបង ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០១៣
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៩០១/១៣ គ.ជ.ប ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

- បានឃើញលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ របស់លោក **សួន ចំរើន** ប្រគល់សិទ្ធិជូនលោកមេធាវី **កែត ឃី** និង លោកមេធាវី **ជួង ជូងី** ដើម្បីការពារនូវសិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់របស់គណបក្សសង្គ្រោះជាតិនៅចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងសំណុំរឿងលេខ ២៣៨/០៤២/២០១៣ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣
- បានឃើញពាក្យសុំតំណាងដោយអាណត្តិចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **កែត ឃី** និងលិខិតតំណាងដោយអាណត្តិចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **ជួង ជូងី**
- បានឃើញសេចក្តីសម្រេចលេខ ០៥០/២០១៣ កបធ.ច ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ របស់លោក **សួន ចំរើន** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១៣ និង ៥០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អនុលោមតាមមាត្រា ១១៥ ថ្មី មាត្រា ១១៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ នៃមាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន
- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់លោក **សួន ចំរើន** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ គឺប្តឹងសុំតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ដើមបណ្តឹងបានរៀបរាប់ថា នៅមណ្ឌលខេត្តបាត់ដំបងមានភាពមិនប្រក្រតីធ្ងន់ធ្ងរក្នុងការបោះឆ្នោត និង ការរាប់សន្លឹកឆ្នោតកាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៣ ដែលមន្ត្រីរៀបចំការបោះឆ្នោតបានរំលោភបំពានច្បាប់បោះឆ្នោត និង បទបញ្ជានីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិដែលត្រូវទទួលបានក្នុងមណ្ឌលខេត្តបាត់ដំបង។ ភាពមិនប្រក្រតីធ្ងន់ធ្ងរនោះមានបីករណីគឺ ÷ ១-បញ្ជីបោះឆ្នោតមានភាពមិនប្រក្រតីដូចមានឯកសារថតចម្លងបញ្ជីឈ្មោះ និង

ស្នាមមេដៃប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតហើយត្រូវគេបោះឆ្នោតជំនួសប្រមាណ ១.៧០០ នាក់ និង ឯកសារនៃបញ្ជីឈ្មោះស្ទួនរហូតដល់ ៣៥.០០០នាក់ ២-តួលេខតាមទម្រង់ ១១០៤ ខុសពីតួលេខបណ្តោះអាសន្នដែលផ្សព្វផ្សាយដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ ។ ក្នុងនោះដើមបណ្តឹងស្នើឱ្យធ្វើការផ្ទៀងផ្ទាត់តាមទម្រង់ ១១០២ និង ១១០៨ ក្នុងកញ្ចប់ "ក"ចំនួន ១១៧ ការិយាល័យ ៣-ភាពមិនប្រក្រតីពេលរាប់សន្លឹកឆ្នោត តាមរបាយការណ៍របស់អ្នកសង្កេតការណ៍តំណាងគណបក្សសង្គ្រោះជាតិថា មានការរាប់ញាប់ពេក មានការប្រកែកគ្នាចំពោះសន្លឹកឆ្នោតមិនបានការ ។ រឿងនេះកើតមាននៅ ១១៦ ការិយាល័យ

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោក **សួន ចំរើន** អមដោយលោកមេធាវី **កែត ឃី** និង លោកមេធាវី **ជូង ជូងី** តំណាងដោយអាណត្តិ បានរៀបរាប់ឡើងវិញនូវខ្លឹមសារដែលមានចែងក្នុងពាក្យបណ្តឹងព្រមទាំងលើកអំពីអង្គច្បាប់ដើម្បីដាក់បន្ទុកលើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អំពីការបើកកញ្ចប់សុវត្ថិភាព"ក" ចំនួន ០៨ ការិយាល័យ នៅក្រុងបាត់ដំបងដើម្បីផ្ទៀងផ្ទាត់ ដើមបណ្តឹងបានលើកឡើងថា មានចំនួនការិយាល័យតិចពេកមិនស្របតាមសំណូមពរ ។ លោក **សួន ចំរើន** បានឆ្លើយនឹងសំណួររបស់ក្រុមប្រឹក្សាជំនុំជម្រះថា ស្ថានភាពនៅខេត្តបាត់ដំបងក្នុងថ្ងៃបោះឆ្នោត មិនមានប្រធានសក្តិ មិនមានអសន្តិសុខ មិនមានបះបោរទេ ប៉ុន្តែមានលក្ខណៈចោរលួចមាន់។ ជាចុងក្រោយតំណាងគណបក្សសង្គ្រោះជាតិសំណូមពរ ÷ ១-បដិសេធសេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចោលទាំងស្រុង ២-អនុញ្ញាតឱ្យ(គជប)ធ្វើការរាប់សន្លឹកឆ្នោតបានការ និងផ្ទៀងផ្ទាត់ឡើងវិញលើសន្លឹកឆ្នោតមិនបានការចំនួន ១១៦ ការិយាល័យក្នុងខេត្តបាត់ដំបង និង ផ្ទៀងផ្ទាត់តួលេខចំនួន ១១៧ ការិយាល័យ ៣-ចាត់ឱ្យមានការស៊ើបអង្កេតឡើងវិញ ថាតើកំហុសទាំងអស់ខាងលើនេះ មានការបង្គាប់បញ្ជាពីត្រឹមថ្នាក់ណា ? ត្រឹមថ្នាក់សមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ឬ ថ្នាក់សមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត ឬ ពីថ្នាក់សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះទៅ ៤-សុំឱ្យមានការផ្តន្ទាទោសលើជនប្រព្រឹត្តល្មើសតាមមាត្រា ១២៥ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់នេះដោយក្តីអនុគ្រោះ
- យល់ឃើញថា ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ អមដោយសារណាការពារចំនួនពីរទំព័រ ក៏ដូចជានៅពេលសវនាការជំនុំជម្រះជាសាធារណៈ បានបញ្ជាក់ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងការដោះស្រាយបណ្តឹងលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត គឺអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១១៤ មាត្រា ១១៥ ថ្មី និងមាត្រា ១១៦ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង

តំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។ ចំពោះការតវ៉ាទាំងឡាយរបស់ដើមបណ្តឹង គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតបានដោះស្រាយតាមដំណាក់កាលនីមួយៗ មានខ្លឹមសារដូចតទៅ ÷

១-បណ្តឹងលើភាពមិនប្រក្រតីនៃបញ្ជីឈ្មោះបោះឆ្នោតបានផុតអាជ្ញាយុកាលតវ៉ាតាំងពីចុងឆ្នាំ២០១២ ម្ល៉េះ

២-តួលេខក្នុងទម្រង់ ១១០៤ ខុសពីតួលេខនៃលទ្ធផលបណ្តោះអាសន្ន ករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអញ្ជើញដើមបណ្តឹង តំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍នានាចូលរួមត្រួតពិនិត្យលទ្ធផល ។ ក្នុងពេលត្រួតពិនិត្យ ដើមបណ្តឹងយកទម្រង់ ១១០៩ ធ្វើដោយខ្លួនឯងមកផ្ទៀងផ្ទាត់ជាមួយទម្រង់ ១១០៩ និង ទម្រង់ ១១០២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ក្នុង ១០២ ឃុំ នៃខេត្តបាត់ដំបង មានតែ ៥៣ ឃុំប៉ុណ្ណោះ ដែលទិន្នន័យរបស់គណបក្សសង្គ្រោះជាតិ និង ទិន្នន័យរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានតួលេខខុសគ្នា ។ ការត្រួតពិនិត្យបង្ហាញថា តួលេខរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រឹមត្រូវ ឯតួលេខរបស់គណបក្សសង្គ្រោះជាតិមិនត្រឹមត្រូវទេ នេះមានន័យថា លទ្ធផលបណ្តោះអាសន្ននៅខេត្តបាត់ដំបង មានភាពត្រឹមត្រូវទាំងអស់

៣-ភាពមិនប្រក្រតីនៅពេលរាប់សន្លឹកឆ្នោត ករណីនេះត្រូវបានបដិសេធចោលតាមស្មារតីនៃបញ្ញត្តិមាត្រា ១១៤ និង មាត្រា ១១៥ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ព្រោះថាអ្នកប្តឹងមិនបានបញ្ជាក់អំពីភាពមិនប្រក្រតីរបស់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ហើយក៏មិនបានផ្តល់សាក្សីព្រមទាំងឯកសារ ឬ ភស្តុតាងដូចមានចែងក្នុងមាត្រា ១១៤ ទេ ។ ម្យ៉ាងទៀតទម្រង់ ១១០២ (កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត) មិនបានបញ្ជាក់ពីភាពមិនប្រក្រតី ឬ ការតវ៉ាក្នុងពេលរាប់សន្លឹកឆ្នោតនោះទេ ហើយទម្រង់នេះក៏បានបិទផ្សាយជាសាធារណៈនៅគ្រប់ការិយាល័យរួចហើយ ។ សរុបសេចក្តីមក បណ្តឹងនេះត្រូវបានបដិសេធតាមមាត្រា ១១៥ ថ្មី ប៉ុន្តែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចេញសេចក្តីសម្រេចតាមការធ្វើសវនាការសង្ខេប ដោយសារគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានយល់ព្រមធ្វើការត្រួតពិនិត្យដោះស្រាយជាសាធារណៈនូវចំណុចទី២ ជូនដើមបណ្តឹង ស្របតាមមាត្រា ១១៦ ថ្មី ។ ឯកឧត្តម **មាន សាទិ** សំណូមពរឱ្យក្រុមប្រឹក្សា-ធម្មនុញ្ញមេត្តារក្សាសេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការ

- យល់ឃើញថា ពេលបើកកញ្ចប់សុវត្ថិភាព"ក"ចំនួន ០៨ ការិយាល័យនៅក្រុងបាត់ដំបង ខេត្តបាត់ដំបង នាថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០១៣ តាមសេចក្តីសម្រេចលេខ ២៩/២០១៣ កបធ.សសរ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានធ្វើនៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បង្ហាញឱ្យឃើញថា កញ្ចប់សុវត្ថិភាព"ក"បិទការសុវត្ថិភាពជិតតាមលក្ខណៈបច្ចេកទេសទាំងអស់ ហើយមានចុះហត្ថលេខាទទួលស្គាល់ពីតំណាងគណបក្សនយោបាយគ្រប់ការិយាល័យទាំង០៨

ហើយមានការិយាល័យចំនួន០២មានតំណាងអង្គការខុមហ្វ្រែលចុះហត្ថលេខាបន្ថែមពីលើតំណាងគណបក្សនយោបាយ ។ ឯសំឡេងគាំទ្រគណបក្សសង្គ្រោះជាតិ និង គណបក្សប្រជាជនកម្ពុជា គឺត្រឹមត្រូវ លើកលែងតែការិយាល័យលេខ ០២០៤ទេ ដែលគណបក្សសង្គ្រោះជាតិទទួលបានលើស ០១(មួយ)សំឡេង ពោលគឺលើក្រដាសកត់ត្រាសំឡេងឆ្នោតមានតែ ២៧៤ ប៉ុន្តែក្នុងទម្រង់ ១១០២ និង ទម្រង់ ១១០៨ សរសេរ ២៧៥ វិញ ។ ទម្រង់ ១១០២ ទាំង ០៨ ការិយាល័យត្រូវបានបិទលើក្តារខៀនផ្សាយដំណឹង ដើម្បីទុកជូនអ្នកចូលរួមអាចពិនិត្យផ្ទៀងផ្ទាត់មើលបាន ។ សូមអានឧបសម្ព័ន្ធស្តីពីកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តបាត់ដំបង

- យល់ឃើញថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៣ នៅមណ្ឌលខេត្តបាត់ដំបងសរុបមាន ១.៤០១ ការិយាល័យ ការបោះឆ្នោតពុំមានជួបករណីប្រធានសក្តិ ពុំមានអំពើហិង្សា និង ពុំមានការបះបោរទេ ។ ប្រជាពលរដ្ឋបានបោះឆ្នោតដោយសម្ងាត់ និង ដោយសេរីដែលមានអត្រា ៦០,៣៦ ភាគរយ
- យល់ឃើញថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

## ចំពោះមុខគូភាគី

**មាត្រា ១.** ទទួលពាក្យបណ្តឹងរបស់លោក **សួន ចំរើន** ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់សេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជំនុំជម្រះជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០១៣ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០១៣

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ. ក្រុមប្រឹក្សាជំនុំជម្រះ

ប្រធាន

ឯក សំអុល

# ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ

ជាតិ សាសនា ព្រះមហាក្សត្រ

## ឧបសម្ព័ន្ធនៃសេចក្តីសម្រេច

## លេខ ១៤៧/០១៦/២០១៣ កបធ.ច

## ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣

## កំណត់ហេតុ

## ស្តីពី

## ការផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព "ក" មួយចំនួន

## នៅមណ្ឌលខេត្តបាត់ដំបង

- យោងសេចក្តីសម្រេចលេខ ២៩/២០១៣ កបធ.សសរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- យោងលិខិតបង្គាប់ការលេខ ៨៧៨/១៣ គ.ជ.ប ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ឆ្នាំពីរពាន់ដប់បី ខែសីហា ថ្ងៃពុធ ទីម្ភៃប្រាំបី វេលាម៉ោងប្រាំពីរ និងសែសិបនាទីព្រឹក នៅសាលសន្និសីទនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តបាត់ដំបង ក្រុងបាត់ដំបង នៅការិយាល័យបោះឆ្នោតលេខ ១១៨៥ ០១៩៣ ០១៨៨ ០២១៦ ០២១៧ ០២០២ ០២០៤ និង ១១២២ ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោត ក្នុងទម្រង់បែបបទលេខ ១១០២ ១១០៨ និងក្រដាសកត់ត្រាសំឡេងឆ្នោត ក្រោមការត្រួតពិនិត្យរបស់ក្រុមស៊ើបអង្កេតក្រុមប្រឹក្សាធម្មនុញ្ញ។

ជាកិច្ចចាប់ផ្តើម ក្រុមត្រួតពិនិត្យនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានជម្រាបអំពីនីតិវិធីនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងយាង និងអញ្ជើញតំណាងក្រុមប្រឹក្សាធម្មនុញ្ញ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អ្នកសារព័ត៌មានជាតិ អន្តរជាតិ ចូលរួមពិនិត្យការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តបាត់ដំបង ក្រុងបាត់ដំបង នៅការិយាល័យបោះឆ្នោតលេខ ១១៨៥ ០១៩៣ ០១៨៨ ០២១៦ ០២១៧ ០២០២ ០២០៤ និង ១១២២ ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោត ក្នុងទម្រង់បែបបទលេខ ១១០២ ១១០៨ និងក្រដាសកត់ត្រាសំឡេងឆ្នោត។ ក្រុមត្រួតពិនិត្យបានធ្វើការបើកកញ្ចប់សុវត្ថិភាព "ក" ធ្វើការផ្ទៀងផ្ទាត់ម្តងមួយៗការិយាល័យនៅចំពោះមុខតំណាងក្រុមប្រឹក្សាធម្មនុញ្ញ គណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អ្នកសារព័ត៌មានជាតិ អន្តរជាតិ។

មុននឹងចាប់ផ្តើមដំណើរការផ្ទៀងផ្ទាត់ ឯកឧត្តម មឹន ស៊ាន តំណាងក្រុមប្រឹក្សាធម្មនុញ្ញ បានមានប្រសាសន៍ជម្រាបជូន តំណាងគណបក្សនយោបាយ និងក្រុមត្រួតពិនិត្យនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអនុវត្តការកិច្ចត្រួតពិនិត្យផ្ទៀងផ្ទាត់តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ឯកឧត្តម គួយ ប៊ុនរឿន តំណាងគណបក្សសង្គ្រោះជាតិ បានស្នើសុំឲ្យមានការត្រួតពិនិត្យផ្ទៀងផ្ទាត់ទាំងអស់មានចំនួន ២៣៣ការិយាល័យ ហើយការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឲ្យផ្ទៀងផ្ទាត់មានតែ ០៨ ការិយាល័យក្នុងក្រុងបាត់ដំបង ទូលបង្គំខ្ញុំយល់ឃើញថា បើយកតែក្រុងបាត់ដំបងមួយ ជាមូលដ្ឋានមានលក្ខណៈតិចតួចណាស់ ហេតុនេះទូលបង្គំខ្ញុំស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញមេត្តាពិនិត្យពិចារណាឡើងវិញ។

លោក អ៊ុក ស៊ុយ តំណាងគណបក្សសង្គ្រោះជាតិ បានស្នើសុំឲ្យក្រុមត្រួតពិនិត្យ ក្រោយពីបើកកញ្ចប់សុវត្ថិភាព "ក" រួចហើយ ស្នើសុំត្រួតពិនិត្យទាំងត្រាសម្ងាត់ និងចំនួនសន្លឹកឆ្នោតជាមួយគ្នាតែម្តង។

ឯកឧត្តម មឹន ស៊ាន បានមានប្រសាសន៍ឆ្លើយតបថា ការសម្រេចផ្ទៀងផ្ទាត់នេះ ត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញសម្រេចរួចហើយ តាមសេចក្តីសម្រេចលេខ ២៩/២០១៣ កបធ.សសរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ការត្រួតពិនិត្យផ្ទៀងផ្ទាត់បានធ្វើការផ្ទៀងផ្ទាត់ម្តងមួយៗ ការិយាល័យទទួលលទ្ធផលដូចខាងក្រោម ៖

## ការិយាល័យលេខកូដ ១១៨៥

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | គ្មាន | ០ | គ្មាន | |
| ២-ហ៊្វុនស៊ិនប៉ិច | ០៦ | ០៦ | ០៦ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០១ | ០១ | ០១ | |
| ៤-ប្រជាជនកម្ពុជា | ១២០ | ១២០ | ១២០ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | គ្មាន | ០១ | ០១ | ទម្រង់ ១១០២ មិនបានកត់ត្រាទិន្នន័យ |
| ៧-សង្គ្រោះជាតិ | ២១០ | ២១០ | ២១០ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៣ | ០៣ | ០៣ | |

<u>កំណត់សម្គាល់</u> ៖

- កញ្ចប់សុវត្ថិភាព "ក" បិទជិត។
- តារាងកត់ត្រាសំឡេងឆ្នោតនៅខាងក្រៅកញ្ចប់សុវត្ថិភាព "ក"។

<u>ការកត់សម្គាល់ភាពមិនប្រក្រតី របស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- ស្នើសុំបូកសរុបសន្លឹកឆ្នោតសរុបក្នុងទម្រង់ ១១០២ ១១០៨ តែមានសន្លឹកឆ្នោតបានការប៉ុន្មាន មិនបានការប៉ុន្មាន។ បើមិនបូកសរុបទេ មិនដឹងថាបានការប៉ុន្មាន មិនបានការប៉ុន្មានទេ។

ព្រោះ ១១០៨ ដែលគណបក្សសង្គ្រោះជាតិបានទទួល បានស្រង់ពីទម្រង់ ១១០២។ បើមិនអញ្ចឹងទេ ពិបាកក្នុងការផ្ទៀងផ្ទាត់។

លោក សួន ចំរើន ៖

- មានបញ្ហាដោយសារក្នុងទម្រង់ ១១០២ គណបក្សតូចៗមិនបំពេញទិន្នន័យ ស្នើសុំលេខាកត់ត្រាបំពេញក្នុងកំណត់ហេតុដោយដាក់ថា គ្មាន។

<u>តំណាងក្រុមប្រឹក្សាធម្មនុញ្ញ</u> ៖

ឯកឧត្តម មឹន ស៊ាន ៖

- សុំឲ្យតំណាងគណបក្សកត់ត្រាទិន្នន័យក្នុងកំណត់ហេតុរបស់ខ្លួន។

## ការិយាល័យលេខកូដ ០១៩៣

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | គ្មាន | ០ | គ្មាន | |
| ២-ហ៊្វុនស៊ិនប៉ិច | ០៦ | ០៦ | ០៦ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | គ្មាន | ០ | គ្មាន | |
| ៤-ប្រជាជនកម្ពុជា | ១២៣ | ១២៣ | ១២៣ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០២ | ០២ | ០២ | |
| ៧-សង្គ្រោះជាតិ | ១៩០ | ១៩០ | ១៩០ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៤ | ០៤ | ០៤ | |

<u>កំណត់សម្គាល់របស់ក្រុមគ្រូតពិនិត្យ</u> ៖

- កញ្ចប់សុវត្ថិភាព "ក" បិទជិត។

<u>ការកត់សម្គាល់ភាពមិនប្រក្រតី របស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- តាមនីតិវិធីដើម្បីចម្លងជូនទិន្នន័យចូលទម្រង់ ១១០២ គឺចម្លងចេញពីតារាង ១១០៨។ ចម្លងពីទម្រង់ ១១០២ មកទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិបានទទួលមិនមានតួលេខសរុប។

លោក អ៊ុក ស៊ុយ ៖

- សុំសំណូមពរឲ្យហៅសំឡេងឆ្នោតបានការ និងមិនបានការ។

<u>តំណាងក្រុមប្រឹក្សាធម្មនុញ្ញ</u> ៖

ឯកឧត្តម មឹន ស៊ាន ៖

- ក្រុមប្រឹក្សាធម្មនុញ្ញមកនេះក្នុងនាមក្រុមប្រឹក្សាធម្មនុញ្ញដើម្បីសង្កេតការណ៍ គឺឲ្យអនុវត្តតាមប្រការ ១ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមគ្រូតពិនិត្យត្រូវលើកបង្ហាញតំណាងគណបក្សនយោបាយ។ ការសម្រេចយ៉ាងណានោះ តំណាងក្រុមប្រឹក្សាធម្មនុញ្ញដែលមកនេះ នឹងយកទៅរាយការណ៍ជូនក្រុមប្រឹក្សាធម្មនុញ្ញដើម្បីសម្រេចពេញអង្គ។
- ទម្រង់ ១១០២ បានបិទនៅលើក្តារខៀនហើយ សុំឲ្យតំណាងគណបក្សអញ្ជើញទៅពិនិត្យ។

## ការិយាល័យលេខកូដ ០១៨៨

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០ | ០ | ០ | |
| ២-ហ៊្វុនស៊ិនប៉ិច | ១១ | ១១ | ១១ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០១ | ០១ | ០១ | |
| ៤-ប្រជាជនកម្ពុជា | ១៥៤ | ១៥៤ | ១៥៥ | គំនូស ១៥៤ ក្រដាសកត់ត្រាសំឡេងឆ្នោតសរសេរ ១៥៥ លើស ០១សំឡេង |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០ | ០ | ០ | |
| ៧-សង្គ្រោះជាតិ | ២១៦ | ២១៦ | ២១៦ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៤ | ០៤ | ០៤ | |

<u>កំណត់សម្គាល់</u> ៖

- កញ្ចប់សុវត្ថិភាព "ក" បិទជិត។
- គំនូសក្រដាសកត់ត្រាសំឡេងឆ្នោតរបស់គណបក្សប្រជាជនកម្ពុជាមាន ១៥៤ ប៉ុន្តែសរុបសរសេរ ១៥៥។

<u>ការកត់សម្គាល់ភាពមិនប្រក្រតី របស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- គណបក្សប្រជាជនកម្ពុជា ១៥៤ ប៉ុន្តែទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិបានទទួលមានតួលេខ ១៥៥។

## ការិយាល័យលេខកូដ ០២១៦

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | | ០៤ | ០៤ | ទម្រង់ ១១០២ មិនបានបំពេញតួលេខសំឡេងឆ្នោតរបស់គណបក្សទាំងអស់។ |
| ២-ហ៊្វុនស៊ិនប៉ិច | | ០៩ | ០៩ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | | ០២ | ០២ | |
| ៤-ប្រជាជនកម្ពុជា | | ១៨២ | ១៨២ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | | ០១ | ០១ | |
| ៧-សង្គ្រោះជាតិ | | ២០៤ | ២០៤ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | | ០៩ | ០៩ | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ</u> ៖

- កញ្ចប់សុវត្ថិភាព "ក" បិទជិត។

- ទម្រង់ ១១០២ មិនបានបំពេញតួលេខសំឡេងឆ្នោតរបស់គណបក្សទាំងអស់។
- ទម្រង់ ១១០២ មានការចុះហត្ថលេខារបស់តំណាងគណបក្សនយោបាយ ឈ្មោះ ចាប លក្ខណា តំណាងគណបក្សសង្គ្រោះជាតិ, ឈ្មោះ លី អេង តំណាងគណបក្សប្រជាជនកម្ពុជា, ឈ្មោះ ដែង សុភី តំណាងគណបក្សហ៊្វុនស៊ិនប៉ិច។

<u>ការកត់សម្គាល់ភាពមិនប្រក្រតី របស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- គណបក្សខ្មែរឈប់ក្រ គណបក្សសង្គ្រោះជាតិបានទទួលបានក្នុងទម្រង់ ១១០៤ មានតួលេខ។ ទម្រង់ ១១០៤ ត្រូវចម្លងពីទម្រង់ ១១០២ ប៉ុន្តែ ១១០២ មិនមានតួលេខទាំងអស់ ដូច្នេះ ជាគោលការណ៍គឺខុសទម្រង់បាត់ទៅហើយ។

## ការិយាល័យលេខកូដ ០២១៧

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០១ | ០១ | ០១ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០២ | ០២ | ០២ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៤ | ០៤ | ០៤ | |
| ៤-ប្រជាជនកម្ពុជា | ១៩៥ | ១៩៥ | ១៩៥ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៣ | ០៣ | ០៣ | |
| ៧-សង្គ្រោះជាតិ | ១៧៤ | ១៧៤ | ១៧៤ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៥ | ០៥ | ០៥ | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ</u> ៖

- កញ្ចប់សុវត្ថិភាព "ក" បិទជិត។

<u>ការកត់សម្គាល់ភាពមិនប្រក្រតី របស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- ទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិបានទទួល សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ និងសន្លឹកឆ្នោតក្នុងហិប មិនបានបំពេញតួលេខទាំងអស់។

## ការិយាល័យលេខកូដ ០២០២

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | 0 | 0 | 0 | |
| ២-ហ៊្វុនស៊ិនប៉ិច | 0 | 0 | 0 | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | 0 | 0 | 0 | |

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ៤-ប្រជាជនកម្ពុជា | ១២៦ | ១២៦ | ១២៦ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០២ | ០២ | ០២ | |
| ៧-សង្គ្រោះជាតិ | ១៦៩ | ១៦៩ | ១៦៩ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៣ | ០៣ | ០៣ | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ</u> ៖

- កញ្ចប់សុវត្ថិភាព "ក" បិទជិត។

<u>ការកត់សម្គាល់ភាពមិនប្រក្រតី របស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- ទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិបានទទួល មានតួលេខតែ ០២ គណបក្ស គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ចំណែកគណបក្សផ្សេងទៀតមិនបានបំពេញតួលេខ។

## ការិយាល័យលេខកូដ ០២០៤

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០៣ | ០៣ | ០៣ | |
| ២-ហ្វ៊ុនស៊ិនប៉ិច | ០៦ | ០៦ | ០៦ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០ | ០ | ០ | |
| ៤-ប្រជាជនកម្ពុជា | ១១២ | ១១២ | ១១២ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០១ | ០១ | ០១ | |
| ៧-សង្គ្រោះជាតិ | ២៧៥ | ២៧៥ | ២៧៤ | ក្រដាសកត់ត្រាសំឡេងឆ្នោត បាត់ ០១សំឡេង |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០២ | ០២ | ០២ | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ</u> ៖

- កញ្ចប់សុវត្ថិភាព "ក" បិទជិត។
- តារាងកត់ត្រាសំឡេងឆ្នោត មិនបានបូកសរុបសំឡេងឆ្នោតគ្រប់គណបក្សនយោបាយ។ ក្រុមត្រួតពិនិត្យបានបូកសរុបឡើងវិញ ដោយមានការឯកភាពពីតំណាងគណបក្សសង្គ្រោះជាតិ ឃើញថា បូកត្រឹមត្រូវ។

<u>ការកត់សម្គាល់ភាពមិនប្រក្រតី របស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

លោក អ៊ុក ស៊ុយ ៖

- ស្នើសុំឲ្យក្រុមត្រួតពិនិត្យធ្វើការចុះហត្ថលេខាលើក្រដាសកត់ត្រាសំឡេងឆ្នោត ដែលក្រុមត្រួតពិនិត្យបានបូក។

ឯកឧត្តម គួយ ប៊ុនរឿន ៖

- ទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិបានទទួល ខុសតួលេខគ្នានឹងទម្រង់ ១១០២ ទម្រង់ ១១០៨ និងក្រដាសកត់ត្រាសំឡេងឆ្នោត រីឯតួលេខសន្លឹកឆ្នោតបានការក៏ខុសគ្នាដែរ។

ក្រុមត្រួតពិនិត្យ ៖

លោក ហ៊ឹ រ៉ុង ប្រធានក្រុមត្រួតពិនិត្យ

- ក្រុមត្រួតពិនិត្យអនុវត្តតាមការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយក៏បានសុំអនុញ្ញាតពីឯកឧត្តមតំណាងក្រុមប្រឹក្សាធម្មនុញ្ញ។

តំណាងក្រុមប្រឹក្សាធម្មនុញ្ញ ៖

ឯកឧត្តម មឹន ស៊ាន ៖

- មតិខ្វែងគំនិតគ្នា លេខាកត់ត្រាត្រូវកត់ត្រាក្នុងកំណត់ហេតុ។

## ការិយាល័យលេខកូដ ១១២២

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | គ្មាន | ០ | ០ | |
| ២-ហ៊្វុនស៊ិនប៉ិច | គ្មាន | ០៦ | ០៦ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | គ្មាន | ០១ | ០១ | |
| ៤-ប្រជាជនកម្ពុជា | គ្មាន | ១២៧ | ១២៧ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | គ្មាន | ០១ | ០១ | ក្រដាសកត់ត្រាសំឡេងឆ្នោតមិនសរុបតួលេខ តំណាងក្រុមប្រឹក្សាធម្មនុញ្ញ និងគណបក្សអនុញ្ញាតឲ្យបំពេញតួលេខសរុប |
| ៧-សង្គ្រោះជាតិ | គ្មាន | ២៦៤ | ២៦៤ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | គ្មាន | ០៣ | ០៣ | |

កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ៖

- កញ្ចប់សុវត្ថិភាព "ក" បិទជិត។
- ទិន្នន័យក្នុងទម្រង់ ១១០២ មិនបានបំពេញតួលេខគ្រប់គណបក្សនយោបាយ។ ក្នុងទម្រង់នេះ មានចុះហត្ថលេខាពីតំណាងគណបក្សឈ្មោះ ព្រហ្ម ហុងឃីម តំណាងគណបក្សសង្គ្រោះជាតិ, ម៉ាត់ ស្រីនាវ តំណាងគណបក្សប្រជាជនកម្ពុជា។

ការផ្ទៀងផ្ទាត់បានបញ្ចប់នៅវេលាម៉ោងដប់ និងហាសិបបីនាទីនាថ្ងៃខែឆ្នាំដដែល។

តំណាងក្រុមប្រឹក្សាធម្មនុញ្ញ

សម្តេច នរោត្តម សិរិវុឌ្ឍ..........

ឯកឧត្តម មីន ស៊ាន..........

ឯកឧត្តម អ៊ិត ឈន..........

ក្រុមលេខាកត់ត្រាក្រុមប្រឹក្សាធម្មនុញ្ញ

លោក ស៊ាន សូលីវុធ..........

លោក ឈុន សុជាតិ..........

លោក ឈុន សៀកហោ..........

តំណាងគណបក្សនយោបាយ

តំណាងគណបក្សសង្គ្រោះជាតិ ៖

លោក សួន ចំរើន..........

ឯកឧត្តម គួយ ប៊ុនរឿន..........

លោក អ៊ុក ស៊ុយ..........

តំណាងគណបក្សប្រជាជនកម្ពុជា ៖

ឯកឧត្តម ស៊ិក ប៊ុនហុក..........

ឯកឧត្តម សៀង ស៊ុតថង..........

តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច ៖

លោក សេក សុជាតិ..........

លោក យារ បូរ៉ា..........

អ្នកសង្កេតការណ៍ជាតិ/អន្តរជាតិ

.......... (VIYA)

.......... COSTF

.......... COMFREL

..........

..........

..........

..........

..........

..........

ក្រុមលេខាកត់ត្រា គ.ជ.ប

លោក កែវ ផល្លា..........

លោក កែ រិទ្ធិ..........

លោក ព្រហ្ម វិចិត្រអក្ខរា..........

លោក ភាព វិរៈ..........

លោក ជោត វ៉ាន់ចាន់..........

លោក អ៊ូ សុផុន..........

ក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់

លោក ហ៊ី រ៉ុង..........

លោក មុំ សុទ្ធ..........

លោក សាត់ សុវណ្ណ..........

លោក ហេង គុច..........

លោក អៀម សុង..........

លោក ម៉ែន សុខសុន្ទី..........

លោក នុត យូវៀម..........

# គណបក្សសង្គ្រោះជាតិ

# CAMBODIA NATIONAL RESCUE PARTY

## សង្គ្រោះ បម្រើ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ.258/.042/.2013
ថ្ងៃ.19. សីហា. 2013...
ម៉ោង..ម៉ោង..13:50..

## ពាក្យបណ្តឹង

ខ្ញុំ សួន ចំរើន ភេទប្រុស អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ២៧៧ ភូមិផ្កាស្លា សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទូរស័ព្ទលេខ ០១២ ៦៤៤៤៨៤ និងជាតំណាងគណបក្សសង្គ្រោះជាតិខេត្តបាត់ដំបង

**សូមគោរពជូន**

**ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ:** ប្តឹងសុំតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប។

**យោង:** -មាត្រា១៥ថ្មី និងមាត្រា១១៧ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

-សម្រង់សេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប តំណាងគណបក្សសង្គ្រោះ បានទទួលនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៦:១៥ នាទី។

តាមកម្មវត្ថុ និងយោងខាងលើនេះ ខ្ញុំសូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបានដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ មណ្ឌលខេត្តបាត់ដំបង ដោយហេតុថា ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ កន្លងមកនេះ កើតមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលមន្ត្រីរៀបចំការបោះឆ្នោតបានរំលោភបំពានច្បាប់បោះឆ្នោត និងបទបញ្ជានីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិដែលត្រូវទទួលបាន ក្នុងមណ្ឌលខេត្តបាត់ដំបង។ ភាពមិនប្រក្រតីធ្ងន់ធ្ងរដែលខ្ញុំប្តឹងទាមទារឲ្យ គ.ជ.ប ពិនិត្យ និងដោះស្រាយរកយុត្តិធម៌នោះមានបីករណីគឺ÷

ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House #576, National Road N°2, Sangkat Chakangres Leu, Khan Mean Chey Phnom Penh, Kingdom of Cambodia
Tel : 012 90 57 75 / 092 92 51 71

-ករណីទី១: បញ្ជីបោះឆ្នោតមានភាពមិនប្រក្រតី ដូចដែលខ្ញុំបានថតចំលងស្នាមមេដៃរបស់ប្រជាពលរដ្ឋដែលបានបាត់ឈ្មោះ និងត្រូវគេបោះជំនួសប្រមាណជា១៧០០នាក់ និងឯកសារនៃបញ្ជីឈ្មោះស្ទួនរហូតដល់៣៥០០០នាក់។

-ករណីទី២: តួលេខតាមទំរង់១១០៤ ខុសពីតួលេខបណ្តោះអាសន្នដែលផ្សព្វផ្សាយដោយ គ.ជ.ប កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣។ ក្នុងនោះខ្ញុំស្នើអោយធ្វើការផ្ទៀងផ្ទាត់តាមទំរង់១១០២ និង១១០៨ ក្នុងកញ្ចប់សុវត្ថិភាព "ក" មានចំនួន ១១៧ការិយាល័យ

-ករណីទី៣: ភាពមិនប្រក្រតីនៅពេលរាប់សន្លឹកឆ្នោត។ ដោយហេតុថា តាមការរាយការណ៍ពីភ្នាក់ងារសង្កេតការណ៍របស់គណបក្សខ្ញុំ មានការរាប់ញាប់ពេក ការប្រកែកគ្នាចំពោះសន្លឹកឆ្នោតមិនបានការ។ មានចំនួន១១៦ការិយាល័យ។

ផ្អែកតាមភាពមិនប្រក្រតីធ្ងន់ធ្ងរទាំងបីករណីខាងលើនេះ ធ្វើឲ្យប៉ះពាល់ដល់លទ្ធផលឆ្នោតរបស់គណបក្សសង្គ្រោះជាតិនៅមណ្ឌលខេត្តបាត់ដំបងធ្ងន់ធ្ងរខ្លាំងណាស់ តែបែរជា គ.ជ.ប សម្រេចសេចក្តីទាំងបំពានច្បាប់ និងបទបញ្ជានីតិវិធី បដិសេធពាក្យបណ្តឹងរបស់ខ្ញុំចោលដោយស្ងាត់ៗដោយមិនបើកសវនាការសាធារណៈ ដើម្បីដោះស្រាយបណ្តឹងស្របតាមមាត្រា ១១៤ និង ១១៦ថ្មីនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីបញ្ជាក់ពីតម្លាភាព ឲ្យអ្នកឈ្នះ ឈ្នះដោយកិត្តិយស និងអ្នកចាញ់ ចាញ់ដោយអស់ចិត្ត។

ក្នុងរឿងនេះខ្ញុំសំណូមពរសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ របស់គ.ជ.ប ចោលជាអសារបង់ ហើយខ្ញុំស្នើសុំទាមទារដល់ក្រុមប្រឹក្សាធម្មនុញ្ញមេត្តាចេញសេចក្តីសម្រេច÷

១-បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីយកទម្រង់ ១១០២ និង១១០៨ ធ្វើការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតចំនួន ១១៧ការិយាល័យ ដូចមានបញ្ជាក់លេខការិយាល័យក្នុងឧបសម្ព័ន្ធ១ មកពិនិត្យនិងផ្ទៀងផ្ទាត់។

២-បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីយកសន្លឹកឆ្នោតទាំង ១១៦ ការិយាល័យ ដូចមានបញ្ជាក់លេខការិយាល័យក្នុងឧបសម្ព័ន្ធ២ មកពិនិត្យផ្ទៀងផ្ទាត់ និងរាប់ឡើងវិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម ឯកឧត្តមប្រធាន មេត្តាផ្តល់នូវភាពយុត្តិធម៌ដល់គណបក្សសង្គ្រោះជាតិ តាមការស្នើសុំខាងលើទៅតាមផ្លូវច្បាប់។

សូម ឯកឧត្តមប្រធាន មេត្តាទទួលនូវការគោរពដោយស្មោះអំពីខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

(ហត្ថលេខា)

សួន ចំរើន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៧៨......អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋផ្ទៃដីទំហំ ២១២៣,៩៩ ហិកតា ស្ថិតនៅភូមិសំរោង ឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រដែលគ្មានដី និងខ្វះដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនិតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ផ្ទៃដីទំហំ ២១២៣,៩៩ ហិកតា (ពីរពាន់មួយរយម្ភៃបីហិកតា និងកៅសិបប្រាំបួនអា) ស្ថិតនៅភូមិសំរោង ឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដូចមានបង្ហាញក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដោយកំណត់តាមចំណុចគោលដែលមាន និយាមកានៃប្រព័ន្ធកូអរដោនេ UTM_ Zone 48 N, WGS 1984 ដូចខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| **1** | 546213 | 1437074 | **14** | 552270 | 1436324 |
| **2** | 546034 | 1437634 | **15** | 552329 | 1435634 |
| **3** | 546747 | 1439814 | **16** | 552491 | 1435204 |
| **4** | 547143 | 1440124 | **17** | 552604 | 1434574 |
| **5** | 548021 | 1439544 | **18** | 552564 | 1434174 |
| **6** | 548231 | 1439774 | **19** | 551218 | 1433764 |
| **7** | 547604 | 1440324 | **20** | 550791 | 1434524 |
| **8** | 548346 | 1440834 | **21** | 551403 | 1435174 |
| **9** | 549424 | 1440164 | **22** | 551314 | 1435584 |
| **10** | 549863 | 1439534 | **23** | 550291 | 1435044 |
| **11** | 551139 | 1438804 | **24** | 549629 | 1434914 |
| **12** | 551503 | 1437484 | **25** | 549288 | 1434664 |
| **13** | 551947 | 1436674 | **26** | 547867 | 1437414 |

**មាត្រា ២.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីដូចមានចែងក្នុងមាត្រា ១ ខាងលើនៃអនុក្រឹត្យនេះដែលជាដីសាធារណៈរបស់រដ្ឋ មកជាដីឯកជនរបស់រដ្ឋ។

**មាត្រា ៣.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានក្នុងមាត្រា ២ ខាងលើ ជូនអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រដែលគ្មានដី ខ្វះដី ហើយត្រូវការដីពិតប្រាកដសម្រាប់សាងសង់លំនៅដ្ឋាន និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី គ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន គសសជ
- គ្រប់សមាជិក គសសជ
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ផែនទីបង្ហាញទីតាំងសម្បទានដីសង្គមកិច្ចទំហំ ២១២៣,៩៩ (ពីរពាន់មួយរយម្ភៃបីក្បៀស កៅសិបប្រាំបួន)ហិកតា

## ស្ថិតនៅ ឃុំ មានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ

ឧបសម្ពន្ធ័អនុក្រឹត្យលេខៈ៤៧៨ អនក្រ.បក.........ចុះថ្ងៃទី...០១.....ខែ កញ្ញា ឆ្នាំ២០១៣




| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 546213 | 1437074 | 14 | 552270 | 1436324 |
| 2 | 546034 | 1437634 | 15 | 552329 | 1435634 |
| 3 | 546747 | 1439814 | 16 | 552491 | 1435204 |
| 4 | 547143 | 1440124 | 17 | 552604 | 1434574 |
| 5 | 548021 | 1439544 | 18 | 552564 | 1434174 |
| 6 | 548231 | 1439774 | 19 | 551218 | 1433764 |
| 7 | 547604 | 1440324 | 20 | 550791 | 1434524 |
| 8 | 548346 | 1440834 | 21 | 551403 | 1435174 |
| 9 | 549424 | 1440164 | 22 | 551314 | 1435584 |
| 10 | 549863 | 1439534 | 23 | 550291 | 1435044 |
| 11 | 551139 | 1438804 | 24 | 549629 | 1434914 |
| 12 | 551503 | 1437484 | 25 | 549288 | 1434664 |
| 13 | 551947 | 1436674 | 26 | 547867 | 1437414 |

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជនទៅក្នុង និងក្រៅប្រទេស ចំនួន ១៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ សាលាធម្មសភា កុដិ បណ្ណាល័យ របងវត្ត ស្រះទឹក ខឿនព្រះវិហារ និងសមិទ្ធផលនានា នៅ**វត្តស្រះក្រាំងបន្ទាយ** ស្ថិតនៅក្នុងឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម ៖

**ក- មេដាយមាសស្ថាបនាជាតិចំនួន ០៧ គ្រឿង ប្រគេន និងផ្តល់ជូន ៖**

១-ព្រះតេជគុណ អេម **សុន** គង់នៅសហរដ្ឋអាមេរិក បច្ច័យចំនួន ២៨.៥៨០ ដុល្លារ

២-ព្រះតេជគុណ ទេន **សម្ផស្ស** ព្រះចៅអធិការវត្តពោធិ៍ដ្ឋាន បច្ច័យចំនួន ១១.៥៥០ ដុល្លារ

៣-ឧបាសិកា **សឹម ឡាង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២៩.៥៧០ ដុល្លារ

៤-ឧបាសិកា **ហៀង ម៉ៅ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២១.៨៥០ ដុល្លារ

៥-ឧបាសក **ដេង ទាសនា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២០.០៥០ ដុល្លារ

៦-លោក **ឡុង ម៉ន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១៣.៧៦៥ ដុល្លារ

៧-ឧបាសិកា **សៀង ហៃ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១២.៥៥០ ដុល្លារ

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៥ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណអធិប្បញ្ញោ គង់ **សំណាង** ព្រះគ្រូសូត្រស្តាំវត្តពោធិ៍ដ្ឋាន បច្ច័យចំនួន ៨.៥៥០ ដុល្លារ

២-ឧបាសិកា **គិន** **អេង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៨.៩៧០ ដុល្លារ

៣-អ្នកគ្រូ **ជា** **សុគន្ធ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៨.៥៥៨ ដុល្លារ

៤-លោកគ្រូ **ម៉ម** **ម៉ានី** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៨.០៧០ ដុល្លារ

៥-ឧបាសក **គាំ** **ផុន** អាចារ្យវត្តស្រះ ថវិកាចំនួន ៥.៥៦០ ដុល្លារ

**គ. មេដាយសំរិទ្ធិស្ថាបនាជាតិចំនួន ០៣ គ្រឿង ផ្តល់ជូន :**

១-ឧបាសក **ឆាំង** **ទ៉េត** អនុប្រធានគណៈកម្មការវត្ត ថវិកាចំនួន ៤.៥៥០ ដុល្លារ

២-លោក **កែ** **ឈួន** គណៈកម្មការសាងសង់វត្ត ថវិកាចំនួន ៤.០៦៧ ដុល្លារ

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តតាកែវ និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៩៧០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្តល់ជូនមន្ត្រីរាជការចំនួន ១៤ រូប ដែលបានខិតខំលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាជាច្រើន និងវិស័យសង្គមកិច្ច ស្ថិតនៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

១-លោក **គោគ សាន** នាយករងវិទ្យាល័យ **ហ៊ុនសែន** កំចាយមារ

២-លោក **គន សុវណ្ណធួន** គ្រូបង្រៀននៅវិទ្យាល័យ **ជា ស៊ីម**

៣-លោក **ស្វ ទាសនា** ប្រធានមណ្ឌលសុខភាពឃុំក្រញូង

៤-លោក **ខាន់ វណ្ណរ៉ាត់** អនុប្រធានការិយាល័យពេទ្យស្រុកប្រតិបត្តិ

៥-លោក **សេង សុខជា** អនុប្រធានការិយាល័យ នៃសាលាខេត្តព្រៃវែង

៦-លោក **ស៊ុម ម៉ុនរេង** អនុប្រធានការិយាល័យពេទ្យស្រុកប្រតិបត្តិ

៧-លោក **ម៉ក់ វណ្ណី** ប្រធានការិយាល័យគាំទ្រឃុំសង្កាត់

៨-លោកវរសេនីយ៍ទោ **ឌឹម ថា** នាយការិយាល័យក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ អត្តលេខ ០៤៨០៩

៩-លោកវរសេនីយ៍ទោ **មាច់ សារាវុធ** នាយរងការិយាល័យក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ អត្តលេខ ០៤៨០៨

១០-លោកវរសេនីយ៍ត្រី **ម៉ែន ណារិទ្ធ** នាយការិយាល័យក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ អត្តលេខ ២៥៥៣៣

១១-លោកវរសេនីយ៍ត្រី **ឥន្ទ វ៉ាន់ធី** នាយសេនាធិការដ្ឋានកងរាជអាវុធហត្ថខេត្ត អត្តលេខ ០២០៥០៤

១២-លោកអនុសេនីយ៍ទោ **អ៊ុក ចិន្តា** នាយរងការិយាល័យក្រុមប្រឹក្សា នីតិកម្មក្រសួងមហាផ្ទៃ អត្តលេខ ២៥៨៨៦

១៣-លោកអនុសេនីយ៍ទោ **ជឹម វណ្ណៈ** នាយរងការិយាល័យក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ អត្តលេខ ០៤៨០៩

១៤-លោកអនុសេនីយ៍ត្រី **ម៉ុត ស៊ីថា** មន្ត្រីនគរបាលការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ច រាជធានីភ្នំពេញ

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៨៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជន និងមន្ត្រីរាជការចំនួន ១៨ រូប ដែលបានខិតខំលះបង់កំលាំងកាយ ចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាជាច្រើន និងវិស័យសង្គមកិច្ច ស្ថិតនៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០២ គ្រឿង ផ្តល់ជូន :**

១-លោក ហៀក អេងឡាយ សប្បុរសជននៅខេត្តព្រៃវែង

២-លោក ពេជ្រ ណន ប្រធានការិយាល័យពេទ្យស្រុកប្រតិបត្តិ

**ខ. មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនាចំនួន ០៣ គ្រឿង ផ្តល់ជូន :**

១-លោក ជា សេងហួត ប្រធានមន្ទីរពេទ្យបង្អែកស្រុកកំចាយមារ

២-លោក ហេង ហ្សូលី មន្ត្រីជាន់ខ្ពស់គម្រោងស៊ីស៊ីចេប

៣-លោកវរសេនីយ៍ត្រី ចិន សំណាង អនុប្រធានប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិកោះរកា អត្តលេខ ៣៤២៥៥

18

**គ- មេដាយមុនីសារាភ័ណ្ឌថ្នាក់អស្សឫទ្ធិចំនួន ០៦ គ្រឿង ផ្តល់ជូន ៖**

១-លោក **និត រចនៈ** គ្រូបង្រៀននៅសកលវិទ្យាល័យ **ជាស៊ីម**

២-លោក **វ៉ែន សិទ្ធី** មន្ត្រីនាយកដ្ឋាននីតិកម្មក្រសួងអប់រំ

៣-លោក **ចិន សុផល្លី** នាយកវិទ្យាល័យ **ហ៊ុន សែន** កំចាយមារ

៤-លោក **សុខ សាលី** ទីប្រឹក្សាសាលាស្រុកកំចាយមារ

៥-លោក **អ៊ុំ សុខ** ប្រធានការិយាល័យកសិកម្មស្រុកកំចាយមារ

៦-លោកអនុសេនីយ៍ត្រី **អេង ម៉ាន់សាក់** មន្ត្រីនគបាល នៃអធិការដ្ឋាននគរបាលក្រុងតាខ្មៅ អត្តលេខ ៥៤៣៩៧

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៨៧៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ៤៤ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តបាការនិវេសន៍ ( ហៅវត្តកំផែង )** ស្ថិតនៅក្នុងសង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៥ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ឧបាសិកា | **អ៊ុក សាឡឹ** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ១៦.៤០០ ដុល្លារ |
| ២-ឧបាសក | **ជា សារឿន** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ១៥.០០០ ដុល្លារ |
| ៣-ឧបាសិកា | **ម៉េង ម៉ៅ** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ១៥.០០០ ដុល្លារ |
| ៤-លោកស្រី | **ជួង វណ្ណា** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ៥-លោក | **ឃួន ប៊ុនធី** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ១២.០០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៩ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក | **ទ្រី ថា** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ៦.០០០ ដុល្លារ |
| ២-លោកស្រី | **ស៊ីវុទ្ធ គណ្ណារី** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ៦.០០០ ដុល្លារ |
| ៣-ឧបាសិកា | **ឆាយ សែម** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ៦.០០០ ដុល្លារ |
| ៤-ឧបាសិកា | **ឡេង ចំរើន** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ៦.០០០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ៥-ឧបាសិកា | **គួច លីណា** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន | ៦.០០០ ដុល្លារ |
| ៦-ឧបាសិកា | **ជា នាង** | សប្បុរសជននៅខេត្តបាត់ | ថវិកាចំនួន | ៦.០០០ ដុល្លារ |
| ៧-ឧបាសក | **ថ្មីន ញ៉** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន | ៦.០០០ ដុល្លារ |
| ៨-ឧបាសក | **ចាន់ គោ** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន | ៥.១៤៨ ដុល្លារ |
| ៩-ឧបាសិកា | **ផាន់ យ៉ែន** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន | ៥.០០០ ដុល្លារ |

**មាត្រា ២ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៧៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ១៥ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តបាការនិវេសន៍ (ហៅវត្តកំផែង)** ស្ថិតនៅក្នុងសង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក- មេដាយមាសការងារចំនួន ០៦ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណគុលធម្មោ **ឃឹម តុល** ព្រះគ្រូសូត្រឆ្វេងវត្តបាការនិវេសន៍
២-ឧបាសក **ជា ណារិន្ទ** អាចារ្យរងវត្តបាការនិវេសន៍
៣-ឧបាសក **សេង សំ** អាចារ្យរងវត្តបាការនិវេសន៍
៤-ឧបាសិកា **ឆា សំអាត** សប្បុរសជននៅខេត្តបាត់ដំបង
៥-ឧបាសិកា **ឆួត អាត** សប្បុរសជននៅខេត្តបាត់ដំបង
៦-ឧបាសិកា **នេង សុខហ៊ាង** សប្បុរសជននៅខេត្តបាត់ដំបង

**ខ- មេដាយប្រាក់ការងារចំនួន ០២ គ្រឿង ផ្តល់ជូន :**

១-ឧបាសិកា **សៅ សន** សប្បុរសជននៅខេត្តបាត់ដំបង
២-ឧបាសិកា **ជុំន ចន្ធូ** សប្បុរសជននៅខេត្តបាត់ដំបង

**គ~ មេដាយសិរីវឌ្ឍិការខាររចំនួន ០៧ គ្រឿង ផ្តល់ជូន :**

| | | |
|---|---|---|
| ១-ឧបាសិកា | **ពេជ្រ តាលុក** | សប្បុរសជននៅខេត្តបាត់ដំបង |
| ២-ឧបាសក | **ឯក សំអុល** | សប្បុរសជននៅខេត្តបាត់ដំបង |
| ៣-ឧបាសក | **ភូ ភឿន** | សប្បុរសជននៅខេត្តបាត់ដំបង |
| ៤-លោក | **សាន្ត ឌីណា** | សប្បុរសជននៅខេត្តបាត់ដំបង |
| ៥-លោក | **ញៀម ហាន** | សប្បុរសជននៅខេត្តបាត់ដំបង |
| ៦-លោក | **កែវ ហាន** | សប្បុរសជននៅខេត្តបាត់ដំបង |
| ៧-លោក | **ញ៉ិយ សារ៉ាត់** | សប្បុរសជននៅខេត្តបាត់ដំបង |

**មាត្រា ២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៨៧៥...អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេន និងផ្ដល់ជូនសប្បុរសជនចំនួន០៥រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តបាការនិវេសន៍ ( ហៅវត្តកំផែង )** ស្ថិតនៅក្នុងសង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១-ព្រះតេជគុណសច្ចកល្យាណោ **ម៉ឿន សាមុត** ព្រះគ្រូសូត្រស្ដាំវត្តបាការនិវេសន៍
២-ព្រះតេជគុណញាណសរណោ **ឃៀប បូរ** គង់នៅប្រទេសអូស្ត្រាលី
៣-ឧបាសិកា **សេង ចាន់លី** សប្បុរសជននៅខេត្តបាត់ដំបង
៤-ឧបាសក **ម៉ក់ សេងលី** សប្បុរសជននៅខេត្តបាត់ដំបង
៥-ឧបាសិកា **តាំង ម៉ោជីង** សប្បុរសជននៅខេត្តបាត់ដំបង

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៧៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក Dr. Robbin Henderson ដែលបានផ្តល់ថវិកាចំនួន ៥៦.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអាងទឹក ចំនួន១៦ និងបង្គន់អនាម័យ ១៦ខ្នង មាន៤៨បន្ទប់ ជូនដល់សាលា ចំនួន១៦កន្លែង ស្ថិតនៅស្រុកបាធាយ ខេត្តកំពង់ចាម ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៧៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនលោក TOZAWA MASAO ដែលបានផ្តល់ថវិកាចំនួន ៤០.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៣បន្ទប់ ជូនដល់សាលាបឋមសិក្សា ស្វាយពក ស្ថិតនៅឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៣
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨៧៧៧.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៣រូប ដែលបានផ្តល់ថវិកាសរុបចំនួន ៦៧.២៨៧ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ ជូនដល់សាលាបឋមសិក្សាបាក់រទេះ ស្ថិតនៅឃុំព្រែកហ្លួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១-Mr. ED SHUTTLEWORTH | ប្រធានអង្គការទស្សនឥតព្រំដែន |
| ២-Mr. MARE THOMAS JANNI | សហស្ថាបនិកសមាគមសម្រេចសុបិនកុមារ |
| ៣-Mr. MI CHAEL BIERSTORFER | សប្បុរសជនអាល្លឺម៉ង់ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧៧៨ . អនក្រ . បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនលោក KIM WOO YEAL ដែលបានផ្តល់ថវិកាចំនួន ២៨.០០០ ដុល្លារអាមេរិក តាមរយៈអង្គការ Lion Clubs ក្នុងការជួយកសាងអគារទីចាត់ការ ០១ខ្នង ទំហំ១២ម៉ែត្រ x ១០ម៉ែត្រ ជូនដល់វិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ព្រៃពោន ស្ថិតនៅភូមិព្រៃពោន ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៣
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ប្រក

# ប្រកាស

# ស្តីពី

# ការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤២៦អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ៧២០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# សម្រេច

**ប្រការ១ ..**

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា ដែលជាមូលដ្ឋានសម្រាប់ក្រសួង ស្ថាប័នក្នុងការរៀបចំ និងដាក់ឲ្យអនុវត្តអង្គភាពថវិកា នៅតាមក្រសួង ស្ថាប័ននីមួយៗ ពិសេស សម្រាប់ក្រសួងដែលត្រូវចាប់ផ្តើមអនុវត្តទាំង១០គឺ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ដែលត្រូវចាប់ផ្តើមអនុវត្តសម្រាប់ការរៀបចំ និងអនុវត្តថវិកាឆ្នាំ២០១៥។

**ប្រការ២ ..**

ក្រសួង ស្ថាប័ន ដែលត្រូវចាប់ផ្តើមអនុវត្តសម្រាប់ការរៀបចំ និងអនុវត្តថវិកាឆ្នាំ២០១៥ ត្រូវរៀបចំអង្គភាពថវិកា ដោយផ្អែកលើគោលការណ៍ណែនាំស្តីពីការរៀបចំ និងចាប់ផ្តើមដាក់ឲ្យអនុវត្តអង្គភាពថវិកា ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ ឯកភាព និងដាក់ឲ្យអនុវត្តតាមរយៈការចេញប្រកាសអន្តរក្រសួង។

**ប្រការ៣ ..**

ប្រកាសលេខ៧២០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពី ការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងអង្គភាពថវិកា ត្រូវទុកជានិរាករណ៍។

**ប្រការ៤ ..**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៥ សហវ.ជម

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៣

# សេចក្តីជូនដំណឹង
## ស្តីពីការផ្ទេរអតិរេកថវិការបស់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ទៅក្នុងគណនីមូលនិធិបំរុងប្រើប្រាស់សម្រាប់ហិរញ្ញប្បទាន ឲ្យចំណាយជាមូលធននៃថវិកាឆ្នាំបន្ទាប់

យោងទៅតាមលិខិតបទដ្ឋានគតិយុត្តិជាធរមានស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក បានកំណត់អតិរេកថវិការបស់រដ្ឋបាលឃុំនៅដំណាច់ឆ្នាំថវិកាត្រូវផ្ទេរទៅគណនីមូលនិធិបំរុងដែលនឹងត្រូវបានប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយជាមូលធននៃថវិកាឆ្នាំបន្ទាប់ រីឯអតិរេកថវិការបស់រដ្ឋបាលសង្កាត់ និងរដ្ឋបាលក្រុង ស្រុកនៅដំណាច់ឆ្នាំថវិកាត្រូវផ្ទេរទៅគណនីលទ្ធផលនៃរតនាគាររាជធានី ខេត្ត។

បច្ចុប្បន្នដោយពិនិត្យឃើញថាថវិការបស់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុកនៅមានទំហំតូចហើយធនធានហិរញ្ញវត្ថុគឺបានមកតែពីប្រភពមូលនិធិមួយមុខប៉ុណ្ណោះ។ ម្យ៉ាងទៀតដោយការយល់ដឹងអំពីជំនាញបច្ចេកទេសផ្នែកហិរញ្ញវត្ថុរបស់មន្ត្រីថ្នាក់ក្រោមជាតិនៅមានកំរិតនៅឡើយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រេចអនុញ្ញាតឲ្យរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុកផ្ទេរអតិរេកថវិកានៅដំណាច់ឆ្នាំទៅក្នុងគណនីមូលនិធិបំរុងដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយមូលធននៃថវិកាឆ្នាំបន្ទាប់រហូតដល់មានការណែនាំជាថ្មី។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត លោកអភិបាលនៃគណៈអភិបាលក្រុង ស្រុក លោកប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត លោកប្រធានរតនាគារ រាជធានី ខេត្ត លោកនាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត លោកប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុក្រុង ស្រុក លោកមេឃុំ និងលោកចៅសង្កាត់មេត្តាជ្រាប និងសហការគ្នាសម្របសម្រួលគាំទ្រឲ្យការរៀបចំនិងអនុវត្តថវិការបស់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុកប្រព្រឹត្តទៅដោយសង្គតិភាព។ ក្នុងករណីជួបបញ្ហាប្រឈមត្រូវរាយការណ៍ជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន។

**កន្លែងទទួល:**

-លេខាធិការដ្ឋាន គ.ជ.អ.ប (ជាពត៌មាន)
-អគ្គនាយកដ្ឋានរតនាគារជាតិ
-នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
-សាលារាជធានី ខេត្ត
-គ្រប់សាលាក្រុង ស្រុក
-គ្រប់សាលាឃុំ សង្កាត់
(ដើម្បីអនុវត្ត)
-គ្រប់មន្ទីរហិរញ្ញវត្ថុរាជធានី ខេត្ត
-គ្រប់រតនាគាររាជធានី ខេត្ត
-គ្រប់ទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត
(ដើម្បី គាំទ្រនិងសម្របសម្រួល)
-ឯកសារ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
លេខ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ១៣៨០/១៣ គ.វ.ក ចុះថ្ងៃទី២១.០៦.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ថាមលេស ហ្វេសសិន ខ្លូស៊ីង ចុះថ្ងៃទី០៦.០៦.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ថាមលេស ហ្វេសសិន ខ្លូស៊ីង (TIMELESS FASHION CLOTHING CO., LTD.) តំណាងដោយ លោក QIN YANG សញ្ជាតិចិន អាយុ៥៦ឆ្នាំកាន់លិខិតឆ្លងដែនលេខE04873868 ចុះថ្ងៃទី១៥.១០.២០១២៨ មានអាសយដ្ឋានបច្ចុប្បន្ន៖ No.306. 5 Buiding, St.,56-1,Bai Xai Area, Nan Jing City, China ជាម្ចាស់រោងចក្រធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

- **ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ថាមលេស ហ្វេសសិន ខ្លូស៊ីង "*
- **ទីតាំងរោងចក្រ ៖** *" ផ្លូវលំ ភូមិថ្នល់បំបែក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យបករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ស៊ុយ សែម**

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤,, "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ៦៦៣ ឧរថ-នឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ១៦៣៨/១៣ គ.វ.គ ចុះថ្ងៃទី១៩.០៧.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ជី អាន ផេភើរ (ខេមបូឌា) ចុះថ្ងៃទី១៦.០៧.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ជី អាន ផេភើរ (ខេមបូឌា) (JI AN PAPER (CAMBODIA) CO.,LTD. តំណាងដោយ លោក ZHAO DAOPING សញ្ជាតិចិន អាយុ៥២ឆ្នាំ កាន់លិខិតឆ្លងដែន លេខ G20394242 ចុះថ្ងៃទី០៦.១១.២០០៧ មានអាសយដ្ឋានបច្ចុប្បន្ន #102, St. 26, An Fu Commune, Ji An District, Jian Xi Province, China ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| កេសកាតុង | ១៧០២ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard. Khan Daun Penh. Phnom Penh. Phone : 855-23-211141 Fax : 855-23-428263

**-ផ្លាកឈ្មោះរោងចក្រ ៖** " *រោងចក្រផលិត កេសកាតុង ជី អាន ផេភើរ (ខេមបូឌា)* "

**-ទីតាំងរោងចក្រ ៖** " *ភូមិបន្លាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ* "

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខៈ ៦៦៤ ឧសថ-កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ១៣១៨ /១៣ គ.វ.ក ចុះថ្ងៃទី១៣.០៦.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន មេគង្គ ហ្គ្រីន ហ្វាម ចុះថ្ងៃទី៣១.០៥.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន មេគង្គ ហ្គ្រីន ហ្វាម (MEKONG GREEN FARM Co., Ltd.) តំណាងដោយ លោក តាន់ វីរៈ សញ្ជាតិខ្មែរ អាយុ៤៨ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 010231029 ចុះថ្ងៃទី០៦.០៤.២០០២ មានអាសយដ្ឋានបច្ចុប្បន្នៈ ផ្ទះលេខ១២៣អឺ០ ផ្លូវ២១៧ ភូមិ៣១ សង្កាត់អូឫស្សី៣ ខណ្ឌ៧មករា រាជធានីភ្នំពេញ ជាម្ចាស់រោងចក្រធ្វើការ បង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោមៈ

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ជ័រកៅស៊ូ | ២២១៩ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855 23 211141 , Fax : 855 23 428263

**ផ្លាកឈ្មោះរោងចក្រ៖** " *រោងចក្រ កែច្នៃជ័រកៅស៊ូ មេគង្គ ហ្វ្រីន ហ្វាម* "
**ទីតាំងរោងចក្រ៖** " *ភូមិជ្រុង ឃុំកក់ ស្រុកបរកែវ ខេត្តរតនគីរី* "

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុង ប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការ រោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុង ប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួល ទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់ សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តរតនគីរី និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តរតនគីរី
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ